Math 08-08-09

រឿង សោភ័ណ្ឌ

កំណែលំហាត់

# គណិតវិទ្យា

ភាគ 1

## ១០

កំណែមានៈ



-គ្រប់លំហាត់

-គ្រប់មេរៀន

-ពន្យល់ក្បោះក្បាយ

© Read and Think Group

# គណិតវិទ្យា ភាគ1

## ថ្នាក់ទី10

បោះពុម្ពផ្សាយដោយ

## ក្រុម អាន និង គិត

**គណៈកម្មការនិពន្ធ និងរៀបរៀង**

លោក អៀង សោភ័ណ្ឌ

**បច្ចេកទេសកុំព្យូទ័រ និងពិនិត្យ**

លោក អៀង សោភ័ណ្ឌ

លោក សុន សៅលី, ក. គឹម ម៉ារ៉ាឌី

យុវសិស្ស

អៀង សោភា,ស្រាង សុធារិទ្ធ,ទីង ឡាយតេរ៉ាង,

ប្បូត សំណាង,គឹម សុទ្ធា

**រចនាក្រប**

លោក អៀង សោភ័ណ្ឌ

© រក្សាសិទ្ធិគ្រប់យ៉ាង, កញ្ញា-2008

# ឯកសារយោង

[1] សៀវភៅ គណិតវិទ្យា ភាគ1+2 ថ្នាក់ទី10(ថ្មី,2008), ក្រសួងអប់រំយុវជន និង កីឡា។

[2] សៀវភៅ គណិតវិទ្យា ភាគ1+2 ថ្នាក់ទី10(ថ្មី,2008) សំរាប់ គ្រូ, ក្រសួងអប់រំយុវជន និង កីឡា។

[3] Math-Problems Vol.1+2+3, រៀង សោភ័ណ្ឌា, ក្រុម អាន និង គិត ។

[4] សៀវភៅ គណិតវិទ្យា ថ្នាក់ទី7,8,9,10,11,12, ក្រសួងអប់រំយុវជន និង កីឡា។

[5] សៀវភៅ គណិតវិទ្យា ថ្នាក់ទី7,8,9,10,11,12, សំរាប់ គ្រូ, ក្រសួងអប់រំយុវជន និង កីឡា។

[6,7,...] និងសៀវភៅយ៉ាងច្រើនទៀត...។

# កថាមុខ

សៀវភៅកំណែ គណិតវិទ្យាថ្នាក់ទី 1០ ភាគ1 រួមមាន ៥ជំពូក។ ដើម្បីជាជំនួយដល់ប្អូនៗសំរាប់ស្វ័យសិក្សា ជាមួយនឹង កម្មវិធីសិក្សាថ្មីនេះ ទើបខ្ញុំបាទរៀបចំកំណែនេះឡើង។

ការរៀបចំកំណែនេះ គឺគ្រប់មេរៀន និងលំហាត់ ដែលសុទ្ធតែយកលំនាំតាម សៀវភៅ គណិតវិទ្យា ភាគ1+២ ថ្នាក់ទី1០(ថ្មី.2008), ក្រសួងអប់រំយុវជន និង កីឡា។

ដើម្បីឲ្យសៀវភៅសិក្សានេះ កាន់តែល្អប្រសើរ យើងខ្ញុំនឹងរង់ចាំទទួលការរិះគន់ និងកែលំអក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សដោយក្តីរីករាយ។

គណៈកម្មការនិពន្ធនិងរៀបរៀង,ភ្នំពេញ, ០៨-០៨-០៨

រឿង សោភ័ណ្ឌា

# និមិត្តសញ្ញាដែលប្រើក្នុងសៀវភៅគណិតវិទ្យា

□,□,□,□,□ : *សំណុំចំនួនគត់ធម្មជាតិ-ចំនួនគត់-សនិទាន-ចំនួនពិត-ចំនួនកុំផ្លិចរៀងគ្នា*

| | | | |
|---|---|---|---|
| $A = \{a, b, c\}$ | : | សំណុំដែលមានធាតុ $a; b; c$ | |
| $\bar{A}$ | : | សំណុំរងបំពេញនៃ $A$ | |
| $\varnothing$ | : | សំណុំទទេ | |
| $n(A)$ | : | ចំនួនធាតុនៃសំណុំ $A$ | |
| $\cup$ | : | ប្រជុំ | $A \cup B$ |
| $\cap$ | : | ប្រសព្វ | $A \cap B$ |
| $\in$ | : | ជាធាតុនៃ | $a \in A$ |
| $\subset$ | : | នៅក្នុង | $A \subset B$ |
| $\wedge$ | : | ឈ្នាប់ និង | $p \wedge q$ |
| $\vee$ | : | ឈ្នាប់ ឬ | $p \vee q$ |
| $\bar{P}$ | : | សំណើឈ្នាប់មិននៃសំណើ $P$ | |
| $\Rightarrow$ | : | ឈ្នាប់នាំឲ្យ | $p \Rightarrow q$ |
| $\Leftrightarrow$ | : | ឈ្នាប់សមមូល | $p \Leftrightarrow q$ |
| ត. $(P)$ | : | តម្លៃភាពពិតនៃសំណើ $p$ | |
| $[a, b]$ | : | ចន្លោះបិទ | $a \le x \le b$ |
| $(a, b)$ | : | ចន្លោះបើក | $a < x < b$ |
| $(a, b]$ | : | ចន្លោះកន្លះបើកខាងឆ្វេង | $a < x \le b$ |
| $[a, b)$ | : | ចន្លោះកន្លះបើកខាងស្តាំ | $a \le x < b$ |
| $\frac{24}{10} = 2.4$ | : | អានថា 2 ចុច 4 | |

| | |
|---|---|
| $P(n, r)$ | ៖ ចម្លាស់នៃ $r$ ធាតុយកពី $n$ ធាតុ |
| $C(n, r)$ | ៖ បន្សំនៃ $r$ ធាតុយកពី $n$ ធាតុ |
| $n!$ | ៖ $n! = 1\times2\times3\times4\ldots\times n$ |
| $\overline{x}$ | ៖ មធ្យម $\overline{x} = \frac{x_1 + x_2 + \ldots x_n}{N}$ |
| $M_e$ | ៖ មេដ្យាន |
| $M_o$ | ៖ ម៉ូត |
| $f(x)$ | ៖ អនុគមន៍នៃ $x$ |
| $\Delta x$ | ៖ កំណើននៃអថេរ |
| $\Delta f$ | ៖ កំណើននៃអនុគមន៍ |
| $A(a, b)$ | ៖ កូអរដោនេនៃចំណុច $A$ |
| sin | ៖ ស៊ីនុស |
| cos | ៖ កូស៊ីនុស |
| tan | ៖ តង់សង់ |
| $AB$ | ៖ អង្កត់ $AB$ ឬ ប្រវែង $AB$ |
| $D$ | ៖ បន្ទាត់ $D$ |
| $\angle A$ | ៖ មុំ $A$ ឬរង្វាស់នៃមុំ $A$ |
| $\overline{AB}$ | ៖ វ៉ិចទ័រ $AB$ |
| $\lvert\overline{AB}\rvert$ | ៖ ប្រវែងនៃវ៉ិចទ័រ $\overline{AB}$ |
| $\vec{u}(a, b)$ | ៖ កូអរដោនេនៃវ៉ិចទ័រ $\vec{u}$ |
| $\vec{u}\cdot\vec{v}$ | ៖ ផលគុណស្កាលែនៃវ៉ិចទ័រ |
| $P$ | ៖ ប្លង់ $P$ |
| $P // Q$ | ៖ ប្លង់ស្របគ្នា |
| $P \perp Q$ | ៖ ប្លង់កែងគ្នា |
| $P \cap Q$ | ៖ ប្លង់ប្រសព្វគ្នា |

# បញ្ជីអត្ថបទ


**ជំពូកទី1 : តក្កវិជ្ជា សំណុំនិងចំនួន** ........ 1

1. តក្កវិទ្យា ........ 1
2. សំណុំ ........ 28
3. ចំនួន ........ 49

**ជំពូកទី2 : ពហុធា** ........ 63

1. ពហុធា ........ 63
2. ប្រមាណវិធីចែកពហុធា ........ 77

**ជំពូកទី3 : សមីការនិងវិសមីការ** ........ 119

1. សមីការដឺក្រេទី2មានមួយអញ្ញាត ........ 119
2. ប្រព័ន្ធសមីការដឺក្រេលំដាប់ខ្ពស់ ........ 132
3. វិសមីការ ........ 145

**ជំពូកទី4 : ធរណីមាត្រក្នុងប្លង់** ........ 165

1. កូអរដោនេនៃចំណុច ........ 165
2. សមីការបន្ទាត់ ........ 173
3. សមីការរង្វង់ ........ 180
4. ដំណោះស្រាយវិសមីការតាមក្រាប ........ 195

**ជំពូកទី5 : អនុគមន៍និងក្រាបអនុគមន៍** ........ 206

1. អនុគមន៍ និងក្រាបនៃអនុគមន៍ ........ 206
2. អនុគមន៍ដឺក្រេទី2និងក្រាបរបស់វា ........ 214
3. អនុគមន៍សនិទាន អនុគមន៍អសនិទាន ........ 228

# មេរៀនទី១ តក្កវិទ្យា

## មេរៀនសង្ខេប

*សំណើគឺជាអំណះអំណាងមួយដែលគេអាចសម្រេចបានជាពិត ឬក៏មិនពិត។

*បើ $p$ ជាសំណើពិត នោះ $p$ មានតម្លៃភាពពិតស្មើនឹង 1 គឺ $ត.(p)=1$ ។

*បើ $p$ ជាសំណើមិនពិត នោះ $p$ មានតម្លៃភាពពិតស្មើនិង 0 គឺ $ត.(p)=0$

*ឈ្នាប់ និង $(\wedge)$: សំណើ $p\wedge q$ ពិតតែក្នុងករណីដែល $p,q$ ជាសំណើពិតទាំងពីរ។

*ឈ្នាប់ ឬ $(\vee)$: សំណើ $p\vee q$ មិនពិតតែក្នុងករណីដែល $p$ និង $q$ ជាសំណើមិនពិតទាំងពីរ។

*ឈ្នាប់ មិន($\overline{\ }$): សំណើ $p$ និង $\overline{p}$ សំណើ មានតំលៃភាពពិតខុសគ្នា។

*ឈ្នាប់ នាំឲ្យ($\Rightarrow$): សំណើ $p \Rightarrow q$ មិនពិតតែក្នុងករណីដែល $p$ ពិត តែ $q$ មិនពិត។ $p$ លក្ខខណ្ឌគ្រប់គ្រាន់ដើម្បី $q$ ។ $q$ ជាលក្ខខណ្ឌចាំបាច់ដើម្បី $p$ ។



*ឈ្នាប់សមមូល($\Leftrightarrow$): សំណើ

$p \Leftrightarrow q$ ពិតតែក្នុងករណីដែលសំណើ $p$ និងសំណើ $q$ មានតម្លៃភាពពិតដូចគ្នា។ $p$ ជាលក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បី $q$ ។

*ប្រភេទនៃសម្រាយបញ្ជាក់ សម្រាយបញ្ជាក់ដោយផ្ទាល់ សម្រាយបញ្ជាក់តាមសំណើផ្ទុយពីសម្មតិកម្ម សម្រាយបញ្ជាក់តាមសំណើផ្ទុយពីការពិត សម្រាយបញ្ជាក់តាមទ្វេលក្ខខណ្ឌ និងសម្រាយបញ្ជាក់តាមឧទាហរណ៍ផ្ទុយ។

## លំហាត់

1. គេមានសំណើពីរ

$p$: ចំនួនសិស្សមធ្យមសិក្សាកំពុងកើនឡើង និង $q$: សិស្សភាគច្រើនចូលចិត្តរៀនគណិតវិទ្យា ។សរសេរជាឃ្លាចំពោះសំណើនីមួយៗដូចខាងក្រោម៖

ក) $p \wedge q$ ខ) $p \vee q$ គ) $\overline{q}$ ។

2. គេមានសំណើពីរ

$p$ : ដារ៉ាជាសិស្សពូកែគណិតវិទ្យា

$q$ : ដារ៉ាដណ្តើមបានមេដាយមាសក្នុងការប្រឡងគណិតវិទ្យា។

ចូរសរសេរសំណើខាងក្រោមដោយប្រើនិមិត្តសញ្ញាតក្កវិទ្យា។

ក, ដារ៉ាជាសិស្សពូកែគណិតវិទ្យា និង ដារ៉ាដណ្តើមបានមេដាយមាសក្នុងការប្រឡងគណិតវិទ្យា។

ខ, ដារ៉ាមិនមែនជាសិស្សពូកែគណិតវិទ្យា។

គ, ដារ៉ាជាសិស្សពូកែគណិតវិទ្យាឬដារ៉ាដណ្តើមបានមេដាយក្នុងការប្រឡងគណិតវិទ្យា។

ឃ, ដារ៉ាជាសិស្សពូកែគណិតវិទ្យាឬដារ៉ាដណ្តើមមិនបានមេដាយមាសក្នុងការប្រឡងគណិតវិទ្យាទេ

3. គេមានសំណើបី ៖

$p$ : សិស្សានុសិស្សដោះស្រាយលំហាត់ដោយលំបាក

q : សិស្សានុសិស្សគិតថាការបង្រៀនរបស់គ្រូមាន
លក្ខណៈល្អ

r : សិស្សានុសិស្សសប្បាយក្នុងការសិក្សា
គណិតវិទ្យា ។

ចូរសរសេរសំណើផ្សំខាងក្រោមដោយប្រើនិមិត្តសញ្ញាតក្កវិទ្យា

ក, សិស្សានុសិស្សដោះស្រាយលំហាត់ដោយលំបាក និងគិតថាការបង្រៀនរបស់គ្រូមានលក្ខណៈមិនល្អ។

ខ, សិស្សានុសិស្សសប្បាយក្នុងការសិក្សាគណិតវិទ្យា និង គិតថាការបង្រៀនរបស់គ្រូមានលក្ខណៈល្អ ។

គ, សិស្សានុសិស្សដោះស្រាយលំហាត់ដោយលំបាក ឬគិតថាការបង្រៀនរបស់គ្រូមានលក្ខណៈមិនល្អ ។

ឃ, សិស្សានុសិស្សដោះស្រាយលំហាត់ដោយលំបាក ឬគិតថាការបង្រៀនរបស់គ្រូមានលក្ខពរាៈល្អ ។

4. សរសេរសំណើបដិសេធនៃសំនើដូចខាងក្រោម

ក, ម៉ាស៊ីនផ្ញើសារជាប់រវល់និងម៉ាស៊ីនថតចំឡងខូច។

ខ, បាល់ទី 1 ពណ៌ស ឬបាល់ទី 2 ពណ៌ក្រហម ។

គ, អាវយឺតមានស្នាមប្រឡាក់ និង មិនមែនលក់នៅហាងសូរិយា ។

5. កំនត់តម្លៃភាពពិតនៃសំណើខាងក្រោម

ក, ផែនដីមានទំហំមិនធំជាងព្រះច័ន្ទទេ ។

ខ, 3+4=7 និង ខែមករាមានចំនួន 32 ថ្ងៃ ។

គ, 3+4=7 ឬ ខែមករាមានចំនួន 32 ថ្ងៃ ។

ឃ, និស្សិតមហាវិទ្យាល័យខ្លះផឹកកាហ្វេ និង និស្សិតទាំងអស់មានទូរស័ព្ទដៃ ។

6. សង់តារាងភាពពិតនៃសំណើនីមួយៗដូចខាងក្រោម

ក) $\overline{p}\vee\overline{q}$ ខ) $\overline{\overline{p}\vee q}$ គ) $p\vee\left(q\wedge\overline{p}\right)$ ។

7. កំណត់តម្លៃភាពពិតនៃសំណើខាងក្រោមតាមករណីនីមួយៗ ខាងក្រោម៖

*ករណីទី 1: $p$ ពិត $q$ មិនពិត និង $r$ ពិត

*ករណីទី 2 : $p$ មិនពិត $q$ មិនពិត និង $r$ ពិត

ក) $\overline{p}\vee(q\wedge r)$ ខ) $(\overline{p}\wedge r)\wedge q$ គ) $(\overline{p}\wedge\overline{q})\vee\overline{r}$

ឃ) $(\overline{p}\vee\overline{q})\vee\overline{r}$ ង) $(p\wedge\overline{q})\vee r$ ។

8. ដោយប្រើតារាងភាពពិត

ចូរបញ្ជាក់គូសំណើដែលសមមូលគ្នា៖

ក) $p\vee\overline{q}$ និង $\overline{p}\wedge q$ ខ) $\overline{p}\wedge q$ និង $\overline{p\vee\overline{q}}$

គ) $q\wedge(\overline{p}\vee q)$ និង $\overline{\overline{p}\vee q}$ ។

9. គេមានសំណើ

$p$ : គ្រាប់ឡុកឡាក់ចេញលេខសេស

$q$ : គ្រាប់ឡុកឡាក់មិនចេញលេខ 5 ។

ដោយប្រើលក្ខណៈរបស់ដឺម៉ដេន (De Morgan) ចំពោះសំណើខាងក្រោម និង សរសេរសំណើដែលបានទាំងនោះឲ្យទៅជាឃ្លាប្រយោគ ។

ក) $\overline{p\wedge q}$ ខ) $\overline{p\vee\overline{q}}$ គ) $\overline{\overline{p}\wedge q}$ ឃ) $\overline{p\wedge\overline{q}}$

ង) $\overline{\overline{p}\vee\overline{q}}$ ។

10. កំនត់តម្លៃភាពពិតនៃសំណើខាងក្រោម:

ក, បើ $10+5=15$ នោះ $56\div 7=8$ ។

ខ, បើ 2 ជាចំនួនគត់គូ 6 និង ជាចំនួនគត់សេស នោះ 15 គឺជាចំនួនគត់សេស

គ, ( ត្រីកោណមួយមាៈនជ្រុង 4 ឬការេមានជ្រុង 3 ) និង ចតុកោណមានជ្រុង 4

11. ដោយប្រើសម្រាយបញ្ជាក់តាមសំណើផ្ទុយពីសម្មតិកម្ម ចូរបង្ហាញថាបើ $x^2-1<0$ នោះ $-1<x<1$ ។

12. សរសេរសំណើផ្ទុយពីសម្មតិកម្មនៃសំណើខាងក្រោម៖

ក) បើខ្ញុំសិក្សាគណិតវិទ្យានោះខ្ញុំនឹងប្រឡងជាប់អាហារូបករណ៍ ។

ខ) បើ $x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន នោះ $x^2$ ជាចំនួនមិនអវិជ្ជមាន ។

គ) បើផែនដីវិលជុំវិញព្រះអាទិត្យ នោះព្រះច័ន្ទ នឹង

វិលជុំវិញផែនដី។

13. ដោយប្រើសម្រាយបញ្ជាក់តាមសំណើផ្ទុយពីការពិត

ក) បង្ហាញថា $\sqrt{5}$ ជាចំនួនអសនិទាន

ខ) បង្ហាញថា $\sqrt{p}$ ជាចំនួនអសនិទានចំពោះគ្រប់ចំនួនបឋម $p$ ។

14. រកឧទាហរណ៍ផ្ទុយពីអំណះអំណាងខាងក្រោម៖

ក) ផលគុណនៃចំនួនអសនិទានពីរខុសគ្នាជាចំនួនអសនិទាន ។

ខ) បើ $x \geq \sqrt{7}$ នោះ $x \geq 3$ ។

គ) $f(n) = n^2 + n + 1$ ជាចំនួនគត់រ៉ឺឡាទីបផង និងជាពហុគុណនៃ $3$ ផងចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីបអវិជ្ជមាន $n$ ។

15. ប្រើសម្រាយបញ្ជាក់តាមសំណើផ្ទុយពីសម្មតិកម្មដើម្បីបង្ហាញករណីខាងក្រោម៖

ក) គេមាន $x$ និង $y$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន និង

$xy$ ជាចំនួនគត់សេស នោះ និង ក៏ជាចំនួនគត់សេសនោះ $x$ និង $y$ ក៏ជាចំនួនគត់សេសដែរ ។

ខ) គេមាន $x(x-2)<0$ នោះ $0<x<2$ ។

## ដំណោះស្រាយ

1). គេមានសំណើពីរ តាងដោយ

$p$ : ចំនួនសិស្សមធ្យមសិក្សាកំពុងកើនឡើង

$q$ : សិស្សភាគច្រើនចូលចិត្តរៀនគណិតវិទ្យា

<u>សរសេរជាឃ្លាចំពោះសំណើ</u>៖

ក) $p\wedge q$ : ចំនួនសិស្សមធ្យមសិក្សាកំពុងកើនឡើង និងសិស្សភាគច្រើនចូលចិត្តរៀនគណិតវិទ្យា ។

ខ) $p\vee q$ : ចំនួនសិស្សមធ្យមសិក្សាកំពុងកើនឡើង រឺ សិស្សភាគច្រើនចូលចិត្តរៀនគណិតវិទ្យា ។

គ) $\overline{q}$ : សិស្សភាគច្រើនមិនចូលចិត្តរៀនគណិតវិទ្យា ។

2). គេមានសំណើពីរ :

$p$ : ដារ៉ាជាសិស្សពូកែគណិតវិទ្យា

$q$ : ដារ៉ាជណ្តើមបានមេដាយមាសក្នុងការប្រលងគណិតវិទ្យា

<u>សរសេរសំណើខាងក្រោមដោយនិមិត្តសញ្ញា តក្កវិទ្យា</u>

ក) ដារ៉ាជាសិស្សពូកែគណិតវិទ្យា ហើយ ដារ៉ាជណ្តើមបានមេដាយមាសក្នុងការប្រលងគណិតវិទ្យា ។ គឺ $p \wedge q$ ។

ខ) $\overline{p}$

គ) $p \vee q$

ឃ) $p \vee \overline{q}$

ង) $\overline{p} \wedge \overline{q}$

3). គេមានសំណើបី៖

$p$ : សិស្សានុសិស្សដោះស្រាយលំហាត់ដោយលំបាក ។

$q$ : សិស្សានុសិស្សគិតថាការបង្រៀនរបស់គ្រូមាន

លក្ខណៈល្អ ។

$r$ : សិស្សានុសិស្សសប្បាយក្នុងការសិក្សា

គណិតវិទ្យា ។

<u>សរសេរសំណើផ្សំដោយប្រើនិមិត្តសញ្ញាតក្កវិទ្យា</u>

ក) $p \wedge \overline{q}$

ខ) $r \wedge q$

គ) $p \vee \overline{q}$

ឃ) $p \wedge q$

4). <u>សរសេរសំណើបដិសេធ</u>៖

ក) ម៉ាស៊ីនផ្ញើសារនៅទំនេរ រឺ ម៉ាស៊ីនថតចំលងមិន

ខូច ។

ខ) បាល់ទី 1 ពណ៌ខុសពី ស និង បាល់ទី 2 ពណ៌ខុស

ពី ក្រហម ។

គ) អាវយឺតគ្មានស្នាមប្រឡាក់ រឺ លក់នៅហាង

សុរិយា ។

5). កំណត់តម្លៃភាពពិតនៃសំណើខាងក្រោម

ក) សំណើមិនពិត

ខ) សំណើមិនពិត

គ) សំណើពិត

ឃ) សំណើមិនពិត

6). <u>សង់តារាងភាពពិតនៃសំណើ</u>៖

ក) $\overline{p} \vee \overline{q}$

| $p$ | $q$ | $\overline{p}$ | $\overline{q}$ | $\overline{p} \vee \overline{q}$ |
|---|---|---|---|---|
| 1 | 1 | 0 | 0 | 1 |
| 1 | 0 | 0 | 1 | 1 |
| 0 | 1 | 1 | 0 | 1 |
| 0 | 0 | 1 | 1 | 1 |

ខ) $\overline{\overline{p} \vee q}$

| $p$ | $q$ | $\overline{p}$ | $\overline{p} \vee q$ | $\overline{\overline{p} \vee q}$ |
|---|---|---|---|---|
| 1 | 1 | 0 | 1 | 0 |
| 1 | 0 | 0 | 0 | 1 |
| 0 | 1 | 1 | 1 | 1 |
| 0 | 0 | 1 | 1 | 0 |

គ) $p \vee \left(q \wedge \overline{p}\right)$

| $p$ | $q$ | $\overline{p}$ | $q \wedge \overline{p}$ | $p \vee \left(q \wedge \overline{p}\right)$ |
|---|---|---|---|---|
| 1 | 1 | 0 | 0 | 1 |
| 1 | 0 | 0 | 0 | 1 |
| 0 | 1 | 1 | 1 | 1 |
| 0 | 0 | 1 | 0 | 0 |

7) កំនត់តម្លៃភាពពិត នៃសំណើខាងក្រោម

<u>ករណីទី 1</u>៖ $p$ ពិត ,$q$ មិនពិត និង $r$ ពិត

ក) $\overline{p}\vee(q\wedge r)$

យើងនិងកំនត់តម្លៃភាពពិតនៃសំណើនេះតាមតារាងភាពពិតដូចខាងក្រោម៖

| $p$ | $q$ | $r$ | $\overline{p}$ | $q\wedge r$ | $\overline{p}\wedge(q\wedge r)$ |
|---|---|---|---|---|---|
| 1 | 0 | 1 | 0 | 0 | 0 |

ដូចនេះ $\left(\overline{p}\vee(q\wedge r)\right)=0$ ។

<u>សំគាល់</u>៖ ចំពោះលំហាត់បន្តបន្ទាប់ទៀតប្អូនៗសាកល្បងព្យាយាមធ្វើតាមគំរូខាងលើ ។

ខ) $\left(\left(\overline{p}\wedge r\right)\wedge q\right)=0$

គ) $\left(\left(\overline{p}\wedge\overline{q}\right)\vee\overline{r}\right)=0$

ឃ) $\left(\left(\overline{p}\wedge\overline{q}\right)\vee\overline{r}\right)=0$

ង) $((p \wedge \overline{q}) \vee r) = 1$

*ករណីទី 2៖ $p$ មិន $q$ មិនពិត និង $r$ ពិត*

ក) 1 ; ខ) 0 ; គ) 1 ; ឃ) 1 ; ង) 1

8). *ដោយប្រើតារាងភាពពិតចូរបញ្ជាក់គូសំណើដែលសមមូលគ្នា៖*

ក) $p \vee \overline{q}$ និង $\overline{p} \wedge q$

| $p$ | $q$ | $\overline{p}$ | $\overline{q}$ | $p \vee \overline{q}$ | $\overline{p} \wedge q$ |
|---|---|---|---|---|---|
| 1 | 1 | 0 | 0 | 1 | 0 |
| 1 | 0 | 0 | 1 | 1 | 0 |
| 0 | 1 | 1 | 0 | 0 | 1 |
| 0 | 0 | 1 | 1 | 1 | 0 |

*តាមតារាងភាពពិត $p \vee \overline{q}$ និង $\overline{p} \wedge q$ ជាសំណើមិនសមមូលគ្នា ។*

<u>សំគាល់</u>៖ *សំណើពីរ រឺ ច្រើនសមមូលគ្នាកាលណាវាមានតំលៃភាពពិតដូចគ្នា ។*

ខ) $\overline{p}\wedge q$ និង $\overline{p\vee\overline{q}}$

| $p$ | $q$ | $\overline{p}$ | $\overline{q}$ | $\overline{p}\wedge q$ | $p\vee\overline{q}$ | $\overline{p\vee\overline{q}}$ |
|---|---|---|---|---|---|---|
| 1 | 1 | 0 | 0 | 0 | 1 | 0 |
| 1 | 0 | 0 | 1 | 0 | 1 | 0 |
| 0 | 1 | 1 | 0 | 1 | 0 | 1 |
| 0 | 0 | 1 | 1 | 0 | 1 | 0 |

តាមតារាងភាពពិតយើងឃើញថាសំណើ $\overline{p}\wedge q$ និង $\overline{p\vee\overline{q}}$ សមមូលគ្នា ។

គ) $q\wedge\left(\overline{p}\wedge q\right)$ និង $\overline{\overline{p}\vee q}$

| $p$ | $q$ | $\overline{p}$ | $\overline{q}$ | $\overline{p}\vee q$ | $q\wedge\left(\overline{p}\vee q\right)$ | $\overline{p}\vee q$ | $\overline{\overline{p}\vee q}$ |
|---|---|---|---|---|---|---|---|
| 1 | 1 | 0 | 0 | 1 | 1 | 1 | 0 |
| 1 | 0 | 0 | 1 | 0 | 0 | 0 | 1 |
| 0 | 1 | 1 | 0 | 1 | 1 | 1 | 0 |
| 0 | 0 | 1 | 1 | 1 | 0 | 1 | 0 |

តាមតារាងភាពពិតយើងបាន៖ $q\wedge(\overline{p}\vee q)$ និង $\overline{\overline{p}\vee q}$ មិនសមមូលគ្នា ។

9). គេមានសំណើ

$p$ : គ្រាប់ឡុកឡាក់ចេញលេខសេស

$q$ : គ្រាប់ឡុកឡាក់មិនចេញលេខ 5

ដោយប្រើលក្ខណៈរបស់ De Morgan ចំពោះសំណើខាងក្រោម និង សរសេរសំណើដែលបានទាំងនោះឲ្យទៅជាឃ្លាប្រយោគ ។

ក) តាមលក្ខណៈ De Morgan យើងបាន

$\overline{p\wedge q}=\overline{q}\vee\overline{p}$ : គ្រាប់ឡុកឡាក់ចេញលេខគូ រឺលេខ 5 ។

ខ) តាមលក្ខណៈ De Morgan យើងបាន

$\overline{p\vee\overline{q}}=\overline{p}\wedge\overline{\overline{q}}=\overline{p}\wedge q$ : គ្រាប់ឡុកឡាក់ចេញលេខគូ ។

គ) តាមលក្ខណៈ De Morgan យើងបាន

$\overline{\overline{p}\wedge q}=\overline{\overline{p}}\vee\overline{q}=p\vee\overline{q}$ :គ្រាប់ឡុកឡាក់ចេញលេខសេស ។

ឃ) តាមលក្ខណៈ De Morgan យើងបាន

$\overline{p \wedge \overline{q}} = \overline{p} \vee \overline{\overline{q}} = \overline{p} \vee q$ : គ្រាប់ឡុកឡាក់ចេញលេខគូ រឺ មិនចេញលេខ 5 ។

ង) តាមលក្ខណៈ De Morgan យើងបាន

$\overline{\overline{p} \vee \overline{q}} = \overline{\overline{p}} \wedge \overline{\overline{q}} = p \wedge q$ : គ្រាប់ឡុកឡាក់ចេញលេខសេស ដែលខុសពីលេខ 5 ។

10). <u>កំនត់តម្លៃភាពពិតនៃសំណើខាងក្រោម៖</u>

ក). បើ $10+5=15$ នោះ៖ $56 \div 7 = 8$

តាង $p: 10+5=15$

$q: 56 \div 7 = 8$

យើងបាន៖ តំលៃភាពនៃ $(p)=1$,

តំលៃភាពនៃ $(q)=1$

សំណើនៃ (ក) ទៅជា៖ $p \Rightarrow q$

គេបាន តំលៃភាពពិត $(p \Rightarrow q)=1$

ដូចនេះ **សំណើខាងលើពិត**

ខ). តាង $p:2$ ជាចំនួនគត់គូ =1

$q:6$ ជាចំនួនគត់សេស =0

$r:15$ ជាចំនួនគត់សេស =1

សំណើនៃសំនួរ (ខ) ទៅជា៖ $(p\wedge q)\Rightarrow r$

យើងនឹងបកស្រាយតាមតារាងភាពពិត

| $p$ | $q$ | $r$ | $p\wedge q$ | $(p\wedge q)\Rightarrow r$ |
|---|---|---|---|---|
| 1 | 0 | 1 | 0 | 1 |

ដូចនេះ តំលៃភាពពិតនៃ $\boxed{\left[(p\wedge q)\Rightarrow r\right]=1}$

គ) តាង $p$ : ត្រីកោណមួយមានជ្រុង $4=0$

$q$ : ការេមានជ្រុង $=0$

$r$ : ចតុកោណមានជ្រុង $4=1$

សំណើនៃសំនួរ គ) ទៅជា :

$(p\vee q)\wedge r$

យើងនិងបកស្រាយតាមតារាងភាពពិត

| $p$ | $q$ | $r$ | $p \vee q$ | $(p \vee q) \wedge r$ |
|---|---|---|---|---|
| 0 | 0 | 1 | 0 | 0 |

ដូចនេះ $\tau\left[(p \vee q) \wedge r\right] = 0$

11) បង្ហាញថាបើ $x^2 - 1 < 0$ នោះ $-1 < x < 1$

តាង $p : x^2 - 1 < 0$

$q : -1 < x < 1$

នាំឱ្យ $\overline{p} : x^2 - 1 \geq 0$

$\overline{q} : x \leq -1 \vee x \geq 1$

ឧបមាថា : $x \leq -1$ ឬ $x \geq 1$

+ចំពោះ $x \leq -1$

នាំឲ្យ : $x^2 \geq 1$ ហើយ $x^2 - 1 \geq 0$ (1)

+ចំពោះ $x \geq 1$

នាំឲ្យ : $x^2 > 1$ ហើយ $x^2 - 1 \geq 0$ (2)

តាម (1)&(2) បញ្ជាក់ថាសំណើ $\overline{p}: x^2 - 1 \geq 0$

ឲ្យយើងទាញបាន : $\overline{q} \Rightarrow \overline{p}$ (ពិត)

ដូចនេះ $p \Rightarrow q$ (ពិត) គឺ

| |
|---|
| បើ $x^2 - 1$ នោះ $-1 < x < 1$ |

12) <u>សសេរសំណើផ្ទុយពីសម្មតិកម្មនៃសំណើ:</u>

ក) បើខ្ញុំប្រលងមិនជាប់អាហារូបករណ៍នោះខ្ញុំមិនសិក្សាគណិតវិទ្យា ។

ខ) បើ $x^2$ zជាចំនួនអវិជ្ជមាននោះ $x$ ជាចមនួនគត់រ៉ឺឡាទីបមិនវិជ្ជមាន ។

គ) បើព្រះច័ន្ទនឹងមិនវិលជុំវិញផែនដីនោះមិននោះមិនវិលជុំវិញព្រះអាទិត្យ ។

13) ដោយប្រើសម្រាយបញ្ជាក់តាមសំនើផ្ទុយពីការពិត

ក) <u>បង្ហាញថា $\sqrt{5}$ ជាចំនួនអសនិទាន</u>

ឧបមា : $\sqrt{5}$ ជាចំនួនសនិទាន

តាង $\sqrt{5}=\frac{a}{b} / a,b\in \mathbb{N}^*$

$\Rightarrow a^2=5b^2$ (1)

យើងបំបែក $a$ និង $b$ ជាផលគុណនៃកត្តាបឋម

យើងបាន : $\begin{cases} a=a_1,a_2,...,a_n \\ b=b_1,b_2,...,b_m \end{cases}$

ដែល $a_i,b_j$ ជាចំនួនបឋម

$i=\overline{1,n}; j=\overline{1m}$ (យើងអចាសរសេរ

$a_1,a_2,...,a_n,b_1,b_2,...,b_m$ ជាចំនួនបឋម)

(1) ទៅជា : $\underbrace{(a_1,a_2,...,a_n)^2}_{\text{មាន } 2n \text{ កត្តា}}=\underbrace{5(b_1,b_2,...,b_m)^2}_{\text{មាន } 2m+1 \text{ កត្តា}}$

យើងសង្កេតឃើញថាអង្គទី១ មានចំនួន

ចំនួនកត្តាបឋមជាចំនួនគូ តែអង្គទី2មានចំនួន

$2m+1$ ចំនួនកត្តាបឋមជាចំនួនសេស ។ នាំឲ្យសមភាព (1) ផ្ទុយពីការពិត ។

ដូចនេះ: $\sqrt{5}$ ជាចំនួនសនិទាន

ខ) បង្ហាញថា

$\sqrt{n}$ ជាចំនួនអសនិទានចំពោះគ្រប់ចំនួនបឋម $p$:

ឧបមា $\sqrt{p}$ ជាចំនួនសនិទាន

តាង $\sqrt{p}=\frac{m}{n} / m,n\in \square ,n\neq 0$

$\Rightarrow m^2 = pn^2 \qquad (1)$

តែ $\begin{cases} m=m_1,m_2,...,m_r \\ n=n_1,n_2,...,n_q \end{cases}$

ដែល $m_1,m_2,...,m_r,n_1,n_2,...,n_q$ ជាចំនួនបឋម ។

(1) ទៅជា

$(m_1,m_2,...,m_r)^2 = p(n_1,n_2,...,n_q)^2$ (ផ្ទុយពីការពិត)

ព្រះអង្គទី1មាន $2n$ កត្តាបឋម តែអង្គទី

(ជំនួសសំនួរ គ.)

ដូចនេះ

| |
|---|
| $\sqrt{p}$ ជាចំនួនអសនិទាន , $\forall p$ បឋម |

14) <u>រកឧទាហរណ៍ផ្ទុយនៃអំណះអំណាង</u>

ក) យក $\sqrt{12}\times\sqrt{13}=\sqrt{36}=6\notin$ □

ខ) យក $x=\sqrt{8}$ តែ $x=\sqrt{8}<3$

គ) យក $n=-1$ នោះ $f(-1)=1\in$ □

តែមិនមែនជាពហុគុណនៃ ទេ ។

15) សម្រាយបញ្ជាក់ផ្ទុយពីសម្មតិកម្ម ដើម្បីបង្ហាញ

ក) គេមាន $x$ និង $y$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាននិង $xy$ ជាចំនួនគត់សេសនោះ $x$ និង $y$ ក៏ជាចំនួនគត់សេសដែរ

ឧបមា $x$ ឬ $y$ ជាចំនួនគត់គូ

យើងបានបីករណីដូចខាងក្រោម

+ករណីទី $x=2k, y=2m+1$

$\Rightarrow xy = 2k(2m+1)$ ជាចំនួនគត់គូផ្ទុយពីសម្មតិកម្ម

+ករណីទី $x = 2k+1, y = 2m$

$\Rightarrow xy = 2m(2k+1)$ ជាចំនួនគត់គូផ្ទុយពីសម្មតិកម្ម

+ករណី $x = 2k, y = 2m$

$\Rightarrow xy = 2k.2m = 2(2mk)$ ជាចំនួនគត់គូផ្ទុយពីសម្មតិកម្ម

ដូចនេះ

| $x$ និង $y$ ជាចំនួនគត់សេស |
|---|

ខ) គេមាន : $x(x-2) < 0$ នោះ $0 < x < 2$

ឧបមា : $x \le 0$ ឬ $x \ge 2$

+ករណី $x \le 0$:

នាំ៖ $x - 2 \le -2$

$\Rightarrow x(x-2) \ge 0$ ផ្ទុយពីសម្មតិកម្ម

+ករណី $x \geq 2$:

នោះ៖ $x-2 \geq 0$

$x(x-2) \geq 0$ ផ្ទុយពីសម្មតិកម្ម

ដូចនេះ៖

$$x(m-2) < 0 \Rightarrow 0 < x < 2$$

# មេរៀនទី2 សំណុំ

## មេរៀនសង្ខេប

★ សំណុំគឺជាបណ្តុំនៃវត្ថុ ដែលកំណត់ដោយលក្ខខណ្ឌជាក់លាក់ ។

★ ចំនួនធាតុនៃសំណុំ $A$ តាងដោយ $n(A)$ ។

★ សំណុំទទេ គឺជាសំណុំដែលគ្មានធាតុសោះ ហើយតាងដោយ $\varnothing$ ។

★ ការកំណត់សំណុំមានពីររបៀប៖ កំណត់តាមការរៀបរាប់ឈ្មោះធាតុ និងកំណត់តាមលក្ខណៈរួមនៃធាតុ ។

★ សំណុំរាប់អស់ជាសំណុំដែលមានចំនួនធាតុជាចំនួនកំណត់ ។

សំណុំអនន្តជាសំណុំដែលមានចំនួនធាតុច្រើនរាប់

មិនអស់ ។

★ សំណុំស្មើគ្នា កាលណាសំណុំទាំងពីរមានបញ្ជីឈ្មោះធាតុដូចគ្នា ។

★ $A$ ជាសំណុំរងនៃ $B$ លុះត្រាតែគ្រប់ $x\in A$ នោះ $x\in B$ ។

★ បើ $A$ ជាសំណុំរងនៃ $B$ នោះ $n(A)\le n(B)$ ។

★ បើ $A$ ជាសំណុំរងផ្ទាល់នៃ $B$ នោះ $n(A)<n(B)$ ។

★ សំណុំសកល គឺជាសំណុំដែលមានគ្រប់ធាតុដែលគេបានជ្រើសរើសយកមកសិក្សា ។

★ សំណុំរងបំពេញ $\overline{A}=\{x/x\notin A, x\in U\}$ ។

★ សំណុំប្រសព្វ $A\cap B=\{x\in A$ និង $x\in B\}$ ។

★ សំណុំប្រជុំ $A\cup B=\{x\in A$ ឬ $x\in B\}$ ។

★ សំណុំ $A$ និង $B$ ជាសំណុំដាច់គ្នា លុះត្រាតែ $A\cap B=\varnothing$ ។

★ ចំពោះគ្រប់សំណុំ $A$ និង សំណុំសកល $U$ គេបាន៖

$A\cap\overline{A}=\varnothing$ , $A\cup\overline{A}=U$ ។

★ បើ $A$ និង $B$ ជាសំណុំរាប់អស់ នោះគេបាន

$n(A\cup B)=n(A)+n(B)-n(A\cap B)$ ។

★ លក្ខណៈដឺម៉ស៊េន (De Morgan)៖

$\overline{A\cup B}=\overline{A}\cap\overline{B}, \overline{A\cap B}=\overline{A}\cup\overline{B}$ ។

★ លក្ខណៈផ្តុំ៖ $A\cap(B\cap C)=(A\cap B)\cap C$

$A\cup(B\cup C)=(A\cup B)\cup C$

★ លក្ខណៈបំបែក៖

$A\cap(B\cup C)=(A\cap B)\cup(A\cap C)$

$A\cup(B\cap C)=(A\cup B)\cap(A\cup C)$

## លំហាត់

1. កំណត់សំណុំតាមការរៀបរាប់ឈ្មោះធាតុ និង កំណត់ចំនួនធាតុនៃសំណុំដូចខាងក្រោម៖

ក. $A=$ សំណុំចំនួនគត់រ៉ឺឡាទីប ដែលធំជាង -2 និងតូចជាង 5 ។

ខ. $B =$ សំណុំចំនួនគត់រ៉ឺឡាទីបដែលធំជាង ឬស្មើ 3 និងតូចជាងឬស្មើ 15 ។

គ. $C = \{x / x$ ជាពហុគុណនៃ 3 និង $1 \le x \le 25\}$

ឃ. $D = \{x / x$ ជាពហុគុណនៃ 5 និង $7 \le 2x \le 25\}$ ។

2. កំណត់សំណុំតាមលក្ខណៈរួមនៃធាតុដោយប្រើនិមិត្តសញ្ញាសំណុំ និងតាមការរាប់ឈ្មោះធាតុ :

ក. $A =$ សំណុំចំនួនគត់សេសវិជ្ជមានតូចជាង 13 ។

ខ. $B =$ សំណុំចំនួនគត់ធម្មជាតិ 7 ចំនួនដំបូងគេ ។

គ. $C =$ សំណុំនៃពហុគុណវិជ្ជមាននៃ 3 ដែលតូចជាង 19 ។

ឃ. $D =$ សំណុំនៃពហុគុណនៃ 5 ដែលនៅចន្លោះពី 4 ដល់ 26 ។

3. គេមានសំណុំ $F = \{x / x$ ជាចំនួនរ៉ឺឡាទីបវិជ្ជមានដែលជាតួចែកនៃ $30\}$ និង $R = \{x / x$ ជាចំនួន

គត់គូនិងជាពហុគុណនៃ ដែល $2 \le x \le 30\}$ ។

ក. កំណត់សំណុំ $F$ និង $R$ តាមការរៀបរាប់ឈ្មោះធាតុ ។

ខ. កំណត់ធាតុនៃ $x$ ដែល $x \in F$ និង $x \in R$ ។

4. គេឲ្យសំណុំ $A = \{x / x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន ដែល $x^2 < 15\}$ និងសំណុំ

$B = \{x / x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន និង $x$ ជាតួចែកនៃ $45$ ។

ក. កំណត់សំណុំ $A$ និងសំណុំ $B$ តាមការរៀបរាប់ឈ្មោះធាតុ ។

ខ. កំណត់ $x$ ដែល $x \in A$ និង $x \in B$ ។

គ. កំណត់សំណុំ $U = \{x / x \in A$ ឬ $x \in B\}$ ។

5. គេឲ្យសំណុំសកល $U = (5,6,7,8,9,10,11,12,13)$ ។

ក. $A = \{x / x \in U$ និង $x$ ជាពហុគុណនៃ $3\}$ ។

ខ. $B = \{x / x \in U$ និង $x$ ជាចែកនៃ $60\}$ ។

គ. $C=\{x/x\in U$ និង $x$ ជាចំនួនបឋម $\}$ ។

6. គេឲ្យសំណុំ $\{x/x=3n+2, n$ ជាចំនួនគត់ធម្មជាតិតូចជាង ឬស្មើ $9\}$ និង $B=\{x/x=6m-1, m$ ជាចំនួនគត់ធម្មជាតិតូចជាង ឬស្មើ $5\}$ ។

ក. កំណត់សំណុំ $A$ និង $B$ តាមការរៀបរាប់ឈ្មោះធាតុ ។

ខ. កំណត់ទំនាក់ទំនងរវាង $A$ និង $B$ ដោយប្រើសញ្ញា $\subseteq$ ។

7. គេឲ្យសំណុំសកល $U=\{x/x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមានដែល $1\le x\le 20\}$ ។

ក. $A=\{x/x$ មិនមែនជាពហុគុណនៃ $3\}$ ។

ខ. $B=\{x/x$ ជាពហុគុណនៃ $3\}$ ។

រួចបង្ហាញថា $n(A)+n(B)=n(U)$ ។

8. គេមានសំណុំសកល $U=\{a,b,c,d,e,f,g,h\}$ ហើយនិងសំណុំរងពីរ $A=\{a,c,e\}$ និង $B=\{b,d,f,h\}$ ។ កំណត់សំណុំ $\overline{A}$ និង $\overline{B}$ តាមការរៀបរាប់ឈ្មោះធាតុ ។ តើ $A$ គឺជាសំណុំរងផ្ទាល់នៃ $\overline{B}$ ដែរឬទេ ?

9. គេឲ្យសំណុំ

$A=\{x/1\le x\le 5\}, B=\{x/0<x<3\}$ និង $C=\{x/|x|>2\}$ ដែល $x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន ។កំណត់សំណុំខាងក្រោម :

ក. $A\cup B$ ។

ខ. $B\cap C$ ។

គ. $\overline{B}\cap C$ ។

10. គេឲ្យសំណុំសកល $U=\{x/x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន $\}$ ហើយនិងសំណុំរងពីរ

$A=\{x/x\in U$ និង $x\geq 5\}$ និង $B=\{x/x\in U$ និង $x<12\}$ ។កំណត់ $n(A\cap B)$ និង $n(\overline{A})$ ។

11. គេតាងចំនួនធាតុនៃសំណុំ $\overline{A},\overline{B}$ និង $A\cap B$ នៅក្នុងដ្យាក្រាមវិន ។ គេឲ្យ $n(\overline{A}\cap B)=n(A\cap\overline{B})$ ។

ក. កំណត់តំលៃ $x$

ខ. កំណត់ $n(A)$ និង $n(B)$ ។

12. គេមានបីសំណុំ $A,B$ និង $C$ ដែល $U=A\cup B\cup C$ ។

តាងដោយចំនួននៃសំណុំវងទាំងបីនៅក្នុងដ្យាក្រាមវិន ។

ក. គេឲ្យ $n(A\cap B)=n(B\cup C)$ ចូររកតំលៃនៃ $x$ ។

ខ. គេឲ្យ $n(B\cap\overline{C})=n(\overline{A}\cap C)$ ចូររកតំលៃនៃ $y$ ។

គ. រក $n(U)$ ។

13. គេមានដ្យាក្រាមវ៉ែនតាងសំណុំបី $A,B$ និង $C$ ។

ចូរគូសឆ្នូតរកសំណុំដូចខាងក្រោម :

ក. $(A\cap B)\cap\overline{C}$ ។

ខ. $(A\cap\overline{B})\cup C$ ។

14. តាមការសម្ភាសអតិថិជនចំនួន 130 នាក់បានឲ្យដឹងថា មានអតិថិជនចំនួន 74 នាក់ចូលចិត្តទិញផលិតផលនៅក្នុងស្រុកចំនួន 70 នាក់ចូលចិត្តទិញផលិតផលបរទេសនិងចំនួន 41 នាក់ចូលចិត្តផលិតផលទាំងពីរនេះ ។ រកចំនួនអតិថិជនដែលចូលចិត្តទិញផលិតផលដូចករណីខាងក្រោម :

ក. ទិញតែផលិតផលក្នុងស្រុក ។

ខ. ទិញតែផលិតផលក្រៅស្រុក ។

គ. មិនទិញផលិតផលទាំងពីរ ។

## ដំណោះស្រាយ

1, <u>កំណត់សំណុំតាមការរៀបរាប់ឈ្មោះធាតុ និងកំណត់ចំនួនធាតុនៃសំណុំខាងក្រោម</u>

ក. $A=\{-1,0,1,2,3,4\}$

$n(A)=6$

ខ. $B=\{3,4,5,6,7,8,9,10,11,12;13,14,15\}$

$n(B)=13$

គ. $C=\{3,6,9,12,15,18,21,24\}$

$n(C)=8$

ឃ. $D=\{5,10,15\}$

$n(D)=3$

2) <u>កំណត់សំណុំតាមលក្ខណៈរួមនៃធាតុដោយប្រើនិមិត្តសញ្ញាសំណុំ និងតាមការរៀបរាប់ឈ្មោះធាតុ:</u>

ក.

$A = \{x / x$ ជាចំនួនគត់សេសវិជ្ជមានតូចជាង$13\}$

$\Rightarrow A = \{1,3,5,7,9,11\}$

ខ. $B = \{x / x$ ជាចំនួនគត់ធម្មជាតិ

7 ចំនួនដំបូងគេ $\}$

$B = \{0,1,2,3,4,5,6\}$

គ. $C = \{x / x$ ជាពហុគុណវិជ្ជ-

ា ដែលតូចជាង $19\}$

$C = \{3,6,9,12,15,18\}$

ឃ. $D = \{x / x$ ជាពហុគុណនៃ

5 ដែលនៅចន្លោះ 4 ដល់ $26\}$

$\Rightarrow D = \{5,10,15,20,25\}$

3) ក. <u>កំនត់សំណុំ $F$ និង $R$ តាមការរៀបរាប់ឈ្មោះធាតុ</u>

មាន : $F = \{x / x \in \mathbb{N}^{+} \wedge$ ជាតួចែកនៃ $30\}$

$\Rightarrow$ $\boxed{F = \{1,2,3,5,6,15,30\}}$

និង $R=\{x/x$ គត់គូ $\wedge$ ជាពហុគុណនៃ $3 \wedge 2 \leq x \leq 30\}$

ខ. <u>កំនត់ធាតុនៃ $x$ ដែល $x \in F \wedge x \in R$</u>

ដោយ $\{6,30\} \in F \wedge \{6,30\} \in R$

ដូចនេះ $\boxed{x \in \{6,30\}}$

4) ក. <u>កំនត់ $A$ និង $B$ តាមការរៀបរាប់ឈ្មោះធាតុ :</u>

មាន : $A=\{x/x \in \square^{+} \wedge x^2 < 15\}$

$\Rightarrow \boxed{A=\{1,2,3\}}$

និង $B=\{x/x \in \square^{+} \wedge$ ជាតួចែកនៃ $45\}$

$\Rightarrow \boxed{B=\{3,5,9,15,45\}}$

ខ. <u>កំនត់ $x$ ដែល $x \in A \wedge x \in B$ :</u>

មាន $A=\{1,2,3\}$

$B=\{3,5,9,15,45\}$

$\Rightarrow \{1,2\} \notin B$

ដូចនេះ $\boxed{x \in \{1,2\}}$

គ. កំណត់ $U$

មាន : $U=\{x/x\in A\vee x\in B\}$

ដោយ : $A=\{1,2,3\}$

$B=\{3,5,9,15,45\}$

ដូចនេះ $\boxed{U=\{1,2,3,5,9,15,45\}}$

5) កំណត់សំណុំខាងក្រោមតាមការរៀបរាប់ឈ្មោះធាតុ

មាន : $U=\{5,7,8,9,10,11,12,13\}$

ក. $A=\{x/x\in U\wedge x$ ជាពហុគុណនៃ $3\}$

$\Rightarrow \boxed{A=\{6,9,12\}}$

ខ. $B=\{x/x\in u\wedge x$ ជាតួចែកនៃ $60\}$

$\Rightarrow \boxed{B=\{5,6,10,12\}}$

គ. $C=\{x/x\in u\wedge x$ បឋម $\}$

$\Rightarrow \boxed{C=\{5,7,11,13\}}$

6) ក. កំណត់ $A$ និង $B$ តាមការរៀបរាប់ឈ្មោះធាតុ

$A=\{x/x=3n+2,n\in ℕ^*,n\leq 9\}$

$$\Rightarrow \boxed{A=\{5,8,11,14,17,20,23,26,29\}}$$

ខ. <u>កំណត់ទំនាក់ទំនង $A$ និង $B$ ដោយប្រើសញ្ញា $\subseteq$</u>

ដោយគ្រប់ធាតុនៃសំណុំ ជាធាតុនៃសំណុំ $A$

ដូចនេះ៖ $\boxed{B\subseteq A}$

7) <u>កំណត់សំណុំរងតាមការរៀបរាប់ឈ្មោះធាតុ</u>

មាន : $U=\{x / x\in \square^{+} \wedge 1\le x\le 20\}$

$\Rightarrow U=\{1,2,3,4,5,...,18,19,20\}$

ក. $A=\{x / x$ មិនមែនជាពហុគុណនៃ $3\}$

$\Rightarrow A=\{1,2,4,5,7,8,10,11,13,14,16,17,19,20\}$

ដូចនេះ៖ $\overline{A}=\{x / x\notin A, x\in U\}$

$$\boxed{A=\{3,6,9,12,15,18\}}$$

ខ. $B=\{x / x$ ជាពហុគុណនៃ $3\}$

$\Rightarrow B=\{3,6,9,12,15,18\}$

$\Rightarrow \overline{B}=\{x / x\notin B, x\in U\}$

ដ.

$$E = \{1,2,4,5,7,8,10,11,13,14,16,17,19,20\}$$

បង្ហាញថា $n(A)+n(B)=n(U)$

មាន $n(A)=14$

$n(B)=6$

$n(U)=20$

$\Rightarrow n(A)+n(B)=14+6=20=n(U)$

ដូចនេះ $n(A)+n(B)=n(U)$

8) +<u>កំណត់ $\overline{A}$ និង $\overline{B}$ តាមការរៀបរាប់ឈ្មោះធាតុ</u>

មាន $U=\{a,b,c,d,e,f,g,h\}$

$A=\{a,c,e\}$

$\Rightarrow \overline{A}=\{x / x\in A, x\in U\}$

$\Rightarrow$ $\overline{A}=\{b,d,f,g,h\}$

ហើយ : $B=\{d,b,f,h\}$

$\Rightarrow \overline{B}=\{x / x\in B, x\in U\}$

$\Rightarrow$ $\boxed{\overline{B}=\{a,c,e,g\}}$

+ដោយ $A=\{a,c,e\}$ នោះ $A$ ជាសំណុំរងផ្ទាល់នៃ $\overline{B}$ ។

៦) <u>កំណត់សំណុំខាងក្រោម :</u>

មាន $x$ ជាចំនួនគត់ធម្មជាតិរ៉ឺឡាទីបរិជ្ជមាន

ហើយ $A=\{x/1\le x\le 5\}$

$\Rightarrow A=\{1,2,3,4,5\}$

$B=\{x/0<x<5\}$

$\Rightarrow B=\{1,2,3,4\}$

$C=\{x/|x|>2\}$

$\Rightarrow C=\{\ \}$

ដូចនេះ ក. $A\cup B=\{0,1,2,3,4,5\}$

ខ. $B\cap C=\varnothing$

គ. $\overline{B}\cap C=\{x/x\ge 3\}$ ។

10) កំណត់ $n(A\cap B)$ និង $n(\overline{B})$

មាន $U=\{x/x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន $\}$

$\Rightarrow U=\{1,2,3,..,\}$

$A=\{x/x\in U\wedge x\geq 5\}$

$\Rightarrow A=\{5,6,7,8,...,\}$

$B=\{x/x\in U\wedge x<12\}$

$=\{1,2,3,4,5,6,7,8,9,10,11\}$

យើងបាន : $A\cap B=\{x\in A\wedge x\in B\}$

$\Rightarrow A\cap B=\{5,6,7,8,9,10,11\}$

ដូចនេះ $\boxed{n(A\cap B)=7}$

ម្យ៉ាងទៀត $\overline{A}=\{x/x\notin A, x\in U\}$

$\Rightarrow \overline{A}=\{1,2,3,4\}$

ដូចនេះ $\boxed{n(\overline{A})=4}$

11) ក. <u>កំណត់តំលៃ</u> $x$

យើងមាន : $n(\overline{A}\cap B)=n(A\cap\overline{B})$

តាមដ្យាក្រាមវ៉ិន, គេបាន

$n(\overline{A}\cap B)=2x-5$

$n(A\cap\overline{B})=x+7$

$\Rightarrow 2x-5=x+7$

$\boxed{x=12}$

ខ. កំ $n(B)$

តាមដ្យាក្រាមវ៉ិន ,គេបាន

$n(A)=(2x-5)+2=2\times12-3=21$

$n(B)=2+x+7=2+12+7=21$

ដូចនេះ៖ $\boxed{n(A)=n(B)=21}$

12) ក. <u>រក x</u>

តាមរូប ,យើងបាន $n(A\cap B)=x$

និង $n(B\cap C)=4$

សម្មតិកម្ម : $n(A\cap B)=n(B\cap C)$

$\Leftrightarrow \boxed{x=4}$

ខ. រក $y$

តាមរូប, យើងបាន $n(B\cap\overline{C})=x+6$

និង $n(\overline{A}\cap C)=4+y$

សម្មតិកម្ម : $n(B\cap\overline{C})=n(\overline{A}\cap C)$

$\Leftrightarrow x+6=4+y$

$\Leftrightarrow y=4+6-4$

$\Leftrightarrow \boxed{y=6}$

គ. រក $n(U)$

មាន $U=A\cup B\cup C$

$\Rightarrow n(U)=8+x+6+4+y$

ដូចនេះ $\boxed{n(U)=8+4+6+4+6=28}$

13) ក. ផ្នែកធូតតាងឲ្យសំណុំ $(A\cap B)\cap\overline{C}$



ខ. ផ្នែកឆូតតាងឲ្យសំណុំ $(A\cap\overline{B})\cup C$




14) ក. <u>ចំនួនអបិតិជនដែលចូលចិត្តទិញផលិតផលក្នុងស្រុក</u>

តាង

$L$ : សំណុំអបិតិជនចូលចិត្តទិញផលិតផលក្នុងស្រុក

$F$ : សំណុំអបិតិជនចូលចិត្តផលិតផលក្រៅស្រុក

$U$ : សំណុំអបិតិជនទាំងអស់

គេបាន $n(L\cap\overline{F})=n(L)-n(L\cap F)$

$=74-41=33$

ដូចនេះ $\boxed{n(L\cap\overline{F})=33}$

ខ.<u>ចំនួនអតិថិជនដែលចូលចិត្តទិញតែផលិតផលក្រៅស្រុក</u>

គេបាន $n\left(F\cap\overline{L}\right)=n(F)-n(L\cap F)$

$$=70-41=29$$

ដូចនេះ $\boxed{n\left(F\cap\overline{L}\right)=29}$

គ. <u>ចំនួនអតិថិជនដែលមិនទិញផលិតផលទាំងពីរប្រភេទ</u>

កំនត់ដោយ

$$n\left(\overline{L\cup F}\right)=n(U)-n(L\cup F) \qquad (*)$$

តែ $n(L\cup F)=n(L)+n(F)-n(L\cap F)$

$$=74+70-41=103$$

$(*)$ ទៅជា : $n\left(\overline{L\cup F}\right)=130-103$

ដូចនេះ $\boxed{n\left(\overline{L\cup F}\right)=27}$

# មេរៀនទី3 ចំនួន

## មេរៀនសង្ខេប

+បន្ទាត់ចំនួន




+លក្ខណៈនៃតំលៃដាច់ខាត $a$:

$|a| = a$ បើ $a \geq 0$

$|a| = -a$ បើ $a < 0$

ចំពោះគ្រប់ចំនួនពិត

$a, |a| \geq 0, |a| = 0$ លុះត្រាតែ $a = 0$ ។

+សំណុំចំនួនគត់ធម្មជាតិ □ $=\{1,2,...,\}$ ។

+សំណុំចំនួនគត់រ៉ឺឡាទីប □ $=\{...,-2,...,\}$ ។

+ចំនួនសនិទានមានទម្រង់ $\frac{m}{n}$ ដែល $m$ និង $n$ ជាចំនួនគត់រ៉ឺឡាទីប

+សំណុំចំនួនសនិទាន តាងដោយ □ ។

ចំណែកថ្នាក់នៃចំនួនពិត

- ចំនួនពិត
  - ចំនួនសនិទាន
    - ចំនួនគត់រ៉ឺឡាទីប
      - ចំនួនគត់រ៉ឺឡាទីបវិជ្ជមាន :1,2,3,...
      - 0
      - ចំនួនគត់រ៉ឺឡាទីបអវិជ្ជមាន :-1,-2,-3
    - មិនមែនចំនួនគត់រ៉ឺឡាទីប : $\frac{1}{8}, \frac{4}{3}, \dots$
  - ចំនួនអសនិទាន : $\sqrt{2}, -\sqrt{3}, \pi, \dots$

+ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a$ និង $b$

គេបាន: $a<b \Leftrightarrow \sqrt{a}<\sqrt{b}$

+ចំពោះ $a>b$ និង $b>0$ គេបាន

: $\sqrt{ab}=\sqrt{a}\sqrt{b}, \sqrt{a^2}=\left(\sqrt{a}\right)^2, \sqrt{\frac{a}{b}}=\frac{\sqrt{a}}{\sqrt{b}}$ ។

+ទម្រង់ពន្លាតនៃចំនួនក្នុងប្រព័ន្ធរាប់គោល 10មានរាង :

$$abcd_2=a\times10^3+b\times10^2+c\times10+d$$

+ ទម្រង់ពន្លាតនៃចំនួនក្នុងប្រព័ន្ធរាប់គោល 2មានរាង:

$$abcd_2=a\times2^3+b\times2^2+d$$ ។

## លំហាត់

1.បញ្ជាក់តម្លៃនៃចំនួនពិត

$x$ ដោយប្រើសញ្ញាវិសមភាពដោយដឹងថា

$x$ ជាចំនួនដែលមានផ្នែកគត់មានលេខពីរខ្ទង់

កាលណាគេសរសេរជាចំនួនទសភាគ ។

2.គណនាកន្សោម $\sqrt{48}-\frac{\sqrt{27}}{2}+\frac{1}{\sqrt{12}}$ ។

3. រកតម្លៃនៃកន្សោមខាងក្រោម

ចំពោះ $x=\frac{1}{\sqrt{7}-\sqrt{5}}$ និង $y=\frac{1}{\sqrt{7}+\sqrt{5}}$ ។

ក) $x+y$ ខ) $xy$ គ) $x^2y+xy^2$ ឃ) $\frac{y}{x}+\frac{x}{y}$

4. ក. សម្រួលកន្សោម $\left(1+\sqrt{2}+\sqrt{3}\right)\left(1+\sqrt{2}-\sqrt{3}\right)$ ។

ខ. បំបាត់រ៉ាឌីកាល់ពីភាគបែងនៃ

ដោយប្រើលទ្ធផលនៃ $\frac{1}{1+\sqrt{2}-\sqrt{3}}$ សំនួរ ក. ។

5. សរសេរចំនួនខាងក្រោមជាទម្រង់ពន្លាត:

ក. 123 ខ. 4321 គ. 65432 ឃ. 123456។

6. សរសេរចំនួនខាងក្រោមទៅជាចំនួនប្រព័ន្ធរាប់គោល10:

ក. $\left(3\times10^5\right)+\left(2\times10^3\right)+\left(1\times10\right)+4$ ។

ខ.

$$\left(8\times10^7\right)+\left(7\times10^6\right)+\left(6\times10^4\right)+\left(5\times10^3\right)+\left(4\times10^2\right)+3$$

គ.

$$\left[\left(3\times10^3\right)+\left(2\times10^2\right)+1\right]+\left[\left(4\times10^4\right)+\left(1\times10^3\right)+\left(1\times10^2\right)+\left(4\times10^1\right)+3\right]$$

7. បំប្លែងចំនួនខាងក្រោមទៅជាចំនួនក្នុងប្រព័ន្ធគោល

ក. $1001_2$ ខ. $100001_2$ ។

គ. $10011001_2$ ឃ. $101010011_2$ ។

8. បំប្លែងចំនួនខាងក្រោមទៅជាចំនួនក្នុងប្រព័ន្ធគោល2:

ក. 19 ខ. 123 គ. 1234 ឃ. 12345។

9. ប្រៀបធៀបចំនួនក្នុងគូចំនួនយនទីមួយៗ ហើយ គណនាផលដករវាងចំនួនទី 1 និងទី 2 ក្នុងគូចំនួនទីមួយៗដូចខាងក្រោម :

ក. $10_{10}$ និង $10_2$ ខ. $100_{10}$ និង $100_2$ គ. $123_{10}$ និង $1101_2$ ។

1) <u>បញ្ជាក់តំលៃនៃចំនួនពិត</u> $x$

យើងសិក្សាលើសំណុំចំនួនពិត □

ដោយដឹងថា $x$ ជាចំនួនដែលមានផ្នែកគត់មានលេខពីរខ្ទង់កាលណាគេសរសេរចំនួនទសភាគ

យើងបាន $[10]=10$ (អានថា $[10]$ ផ្នែកគត់នៃ 10)

$[10,1]=10$

.

.

.

$[99,1]=99$ ជាលេខពីរខ្ទង់

$[99,9]=99$ ជាលេខពីរខ្ទង់

តែ $[100]=100$ ជាលេខបីខ្ទង់ (មិនយក)

ដូចនេះ: $10 \le x < 100$

2) <u>គណនា</u>

$$\sqrt{48}-\frac{\sqrt{27}}{2}+\frac{1}{\sqrt{12}}$$

$$=4\sqrt{3}-\frac{3\sqrt{3}}{2}+\frac{\sqrt{12}}{12}$$

$$=4\sqrt{3}-\frac{3\sqrt{3}}{2}+\frac{\sqrt{3}}{6}$$

$$=\frac{24\sqrt{3}-9\sqrt{3}+\sqrt{3}}{6}$$

$$\frac{14\sqrt{3}}{6}=\boxed{\underline{8\sqrt{3}}}$$

3) រកតំលៃនៃកន្សោម

ចំពោះ $x=\frac{1}{\sqrt{7}-\sqrt{5}}$

$$y=\frac{1}{\sqrt{7}+\sqrt{5}}$$

ក. $x+y=\frac{1}{\sqrt{7}-\sqrt{5}}+\frac{1}{\sqrt{7}+\sqrt{5}}$

$$=\frac{\sqrt{7}+\sqrt{5}+\sqrt{7}-\sqrt{5}}{\left(\sqrt{7}-\sqrt{5}\right)\left(\sqrt{7}+\sqrt{5}\right)}$$

$$=\frac{2\sqrt{7}}{7-5}$$

ដូចនេះ · $\boxed{x+y=\sqrt{7}}$

ខ. $x.y=\frac{1}{\sqrt{7}-\sqrt{5}}.\frac{1}{\sqrt{7}+\sqrt{5}}=\frac{1}{\sqrt{7^2}-\sqrt{5^2}}$

$$=\frac{1}{7-5}=\frac{1}{2}$$

ដូចនេះ $\boxed{xy=\frac{1}{2}}$

គ. $x^2y+xy^2=xy(x+y)$

$$=\frac{1}{2}\left(\sqrt{7}\right)$$

ដូចនេះ $\boxed{x^2y+xy^2=\frac{\sqrt{7}}{2}}$

ឃ. $\frac{y}{x}+\frac{x}{y}=\frac{x^2+y^2}{xy}$

$$=\frac{(x+y)^2-2xy}{xy}$$

$$=\frac{\left(\sqrt{7}\right)^2-2.\frac{1}{2}}{\frac{1}{2}}=12$$

ដូចនេះ $\frac{x}{y}+\frac{y}{x}=12$

4) ក. សំរួលកន្សោម

$$\left(1+\sqrt{2}+\sqrt{3}\right)\left(1+\sqrt{2}-\sqrt{3}\right)$$

$$=\left[\left(1+\sqrt{2}\right)+\sqrt{3}\right]\left[\left(1+\sqrt{2}\right)-\sqrt{3}\right]$$

$$=\left(1+\sqrt{2}\right)^2-\sqrt{3^2}=1+2\sqrt{2}+2-3$$

$$=\boxed{2\sqrt{2}}$$

ខ. <u>បំបាត់រ៉ាឌីកាល់ពីភាគបែង</u>

$$\frac{1}{1+\sqrt{2}-\sqrt{3}}=\frac{\left(1+\sqrt{2}\right)+\sqrt{3}}{\left[\left(1+\sqrt{2}\right)\right]\left[\left(1+\sqrt{2}\right)+\sqrt{3}\right]}$$

$$=\frac{1+\sqrt{2}+\sqrt{3}}{2\sqrt{2}}$$

$$= \boxed{\frac{2+\sqrt{2}+\sqrt{6}}{4}}$$

5. សរសេរចំនួនខាងក្រោមជាទម្រង់ពន្លាត :

ក. $123 = 1\times10^2 + 2\times10 + 3$

ខ. $4321 = 4\times10^3 + 3\times10^2 + 2\times10 + 1$

គ. $65432 = 6\times10^4 + 5\times10^3 + 4\times10^2 + 3\times10 + 2$

ឃ. $123456 = 1\times10^5 + 2\times10^4 + 3\times10^3 + 4\times10^2 + 5\times10 + 6$

6. សរសេរចំនួនខាងក្រោមទៅជាចំនួនក្នុងប្រព័ន្ធរាប់គោល 10:

ក. $(3\times10^5) + (2\times10^3) + (1\times10) + 4$

$= 300000 + 2000 + 10 + 4$

$= \boxed{302014}$

ខ.

$(8\times10^7)+(7\times10^6)+(6\times10^4)+(5\times10^3)+(4\times10^2)+3$

$=80000000+7000000+60000+5000+400+3$

$=$ 87065403

គ.

$[(3\times10^3)\times(2\times10^2)+1]+[(4\times10^4)+(1\times10^3)+(1\times10^2)+(4\times10^1)+3]$

$=3201+41143$

$=$ 44344

7. <u>បំប្លែងចំនួនខាងក្រោមទៅចំនួនក្នុងប្រព័ន្ធគោល 10:</u>

ក. $1001_2=1\times2^3+0\times2^2+0\times2^1+1$

$=$ 9

ខ.

$100001_2=1\times2^5+0\times2^4+0\times2^3+0\times2^2+0\times2^1+1$

$= \boxed{33}$

គ. $10011001_2 = 1\times2^7 + 0\times2^6 + 0\times2^5 +$

$1\times2^4 + 0\times2^3 + 0\times2^2 + 1\times2^1 + 1$

$= 128 + 16 + 8 + 1$

$= \boxed{153}$

ឃ. $101010011_2 = 1\times2^8 + 0\times2^7 + 1\times2^6 +$

$0\times2^5 + 1\times2^4 + 0\times2^3 + 0\times2^2 + 1\times2^1 + 1$

$= 256 + 64 + 16 + 2 + 1$

$= \boxed{339}$

8. <u>បំប្លែងចំនួនខាងក្រោមទៅជាចំនួនក្នុងប្រព័ន្ធគោល 2</u>:

ក. $19 = 10011_2$

ខ. $123 = 1111011_2$

គ. $1234 = 1001101001_2$

ឃ. $12345 = 110000001\ 101_2$

<u>*សំគាល់ :*</u>

*សូមមើលមេរៀននៅក្នុងសៀវភៅពុម្ពសិស្សត្រង់ទំព័រ 47 ផ្នែក ឃ. ។*

9. *ប្រៀបធៀបចំនួនក្នុងគូនីមួយៗហើយគណនាផលដករវាងចំនួនទី1 និងទី2ក្នុងគូនីមួយៗខាងក្រោម:*

ក. $10_2$ និង $10_{10}$

មាន $10_2 = 1\times 2 + 0 = 2_{10}$

$\Rightarrow 10 > 2_{10} = 10_2$

*ដូចនេះ* $\boxed{\begin{array}{l} 10_{10} - 10_2 = 8_{10} \\ 10_{10} > 10_2 \end{array}}$

ខ. $100_{10}$ និង $100_2$

មាន $: 100_2 = 1\times 2^2 + 1\times 2 + 10 = 4_{10}$

$\Rightarrow 100_{10} > 4_{10} = 1002$

ដូចនេះ៖

$$100_{10} - 100_2 = 96_{10}$$
$$100_{10} > 100_2$$

គ. $123_{10}$ និង $1101_2$

ដោយ $1101_2 = 13_{10}$

ដូចនេះ៖

$$123_{10} - 1101_2 = 110_{10}$$
$$123_{10} > 1101_2$$

## លំហាត់ជំពូកទី 1

1. គេមានសំណើ $p$ : ចំនួនសិស្សថយ

$q$ : សិស្សភាគច្រើនចូលចរៀនភាសាខ្មែរ

សរសេរជាឃ្លាចំពោះសំណើនីមួយៗដូចខាងក្រោម:

ក. $\overline{p} \wedge q$ ខ. $p \vee \overline{q}$ ។

2. គេមានសំណើ "បើការសម្ភាសធ្វើការរបស់អ្នកបានលទ្ធផលល្អ នោះអ្នកនិងបានការងារធ្វើ "។

បើសិនជាអ្នកបានសម្ភាស និងបានការងារធ្វើ តើអ្នកសន្និដ្ឋានថាការសម្ភាសរបស់អ្នកបានលទ្ធផលល្អដែរឬទេ ? ចូរពន្យល់ ? ។

3. គេឲ្យសំ.ណុំសាកល

$U = \{x / x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមានដែល $1 \leq x \leq 20\}$ ។

ក.កំនត់សំណុំរងខាងក្រោមតាមការរៀបរាប់ឈ្មោះជាតុ :

$A = \{x / x\ 2\}$ ជាពហុគុណនៃ

$B = \{x / x$ ជាពហុគុណនៃ $3\}$

$C = \{x / x$ ជាពហុគុណនៃ $6\}$

ខ. កំណត់តម្លៃភាពពិតនៃសំណើទីមួយៗ

$C \subset A; B \subset A, C \subset B$ ។

4. កំណត់គ្រប់ចំនួនគតើធ្មជាតិពី $1$ ដល់ $100$ ដែលជាពហុគុណនៃ $3$ និង ជាពហុគុណនៃ $5$ ។

5. គេឲ្យសំណុំសាកល

$U = \{x / x$ ជាចំនួនគត់ធម្មជាតិដែល $3 \le x \le 20\}$ និងសំណុំរងពីរ

$A = \{x / x$ ជាចំនួនគត់សេស $\}$ និង

$B = \{x / x$ ជាចំនួនបឋម $\}$ ។

ក. កំណត់សំណុំ $A$ និង $B$ តាមការរៀបរាប់ឈ្មោះជាតុ

ខ. រំណាត់សំណុំ $C=\{x/x\in A$ និង $x\in B\}$ និង $D=\{x/x\in A$ ឬ $x\in B\}$ តាមការរៀបរាប់ឈ្មោះធាតុ ។ តើគេអាចថាយ៉ាងណាចំពោះសំណុំ $C$ និង $B$ សំណុំ $D$ និង $A$ ?

6. រកលក្ខខណ្ឌនៃសំណើពីរ $p$ និង $q$ ដើម្បីឲ្យសំណើ តាមការរៀបរាប់តាមករណីដូចខាងក្រោម :

ក. ($p$ និង $q$) ពិត

ខ. មិន ($p$ ឬ $q$) ពិត ។

គ. ($p$ និង $q$) មិនពិត

ឃ. មិន ($p$ ឬ $q$) មិនពិត ។

7. $p$ ជាសំណើពិត $q$ ជាសំណើមិនពិត $r$ និង ជាសំណើពិត ។

កំណត់តម្លៃភាពពិតនៃសំណើៈដូចខាងក្រោម :

ក. $(p\vee\overline{q})\wedge(\overline{p\wedge r})$ ។

ខ. $(\overline{r}\vee\overline{p})\vee\overline{q}$ ។

គ. $\left(\bar{p}\vee\bar{q}\right)\vee\left(\bar{r}\vee q\right)$ ។

ឃ. $\left(\bar{r}\vee\bar{q}\right)\wedge\left(\bar{r}\vee\bar{p}\right)$ ។

8. រកឧទាហរណ៍ផ្ទុយនៃអំណះអំណាងខាងក្រោម:

ក.

$f(x)=x^2-27x+k, k\in\square, f(x)=0$ មានឫសបី ចំពោះគ្រប់តម្លៃ $k$ ។

ខ. $f(n)=(n+1)(n+2)(n+3)$ ចែកដាច់នឹង 12 ចំពោះគ្រប់តម្លៃ $n$ ។

9. គេឲ្យសំណុំ

$G=\{x/x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមានដែល $3x<5$ ឬ $5<x\leq 8\}$ និងសំណុំ $p=\{x/x$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមានដែល$10\leq 3x+24\}$ ។

ក. កំណត់សំណុំ $G$ និង $p$ តាមការរៀបរាប់ឈ្មោះធាតុ

ខ. កំណត់ធាតុ $x$ ដែល $x\in G$ និង $x\notin p$ ។

10. គេឲ្យសំណុំសាកល $U=\{x/x$ ជាចំនួនគត់វិជ្ជមានទីបនិង $3\le x\le 8\}$ ។ $A=\{x/10<x^2\le 25\}$ និង $B=\{x/8x-9>30\}$ ជាសំណុំរងនៃ $U$ ។

ក. កំណត់សំណុំ $A$ និង $B$ តាមការរៀបរាប់ឈ្មោះធាតុ ។ រកធាតុ $x$ ដែល $x\in A$ និង $x\notin B$ ។

ខ. តើ $A\subseteq B$ ជាសំណើពិតឬទេ ?

11. តាមការសម្ភាសអតិថិជនចំនួន 145 នាក់ បានឲ្យដឹងថា មានអតិថិជនចំនួន 90 នាក់ចូលចិត្តទិញអាវចំនួន 50 នាក់ចូលចិត្តទិញខោ និងចំនួន 41 នាក់ចូលចិត្តទិញទាំងអាវនិងខោ ។

រកចំនួនអតិថិជនដែលចូលចិត្តទិញដូចករណីខាងក្រោម :

ក. ទិញតែអាវ ។

ខ. ទិញតែខោ ។

គ. មិនទិញអ្វីសោះ ។

12. គេឲ្យចំនួនពិតមិនសូន្យ $a$ និង $b$ ដែល $A=ab, B=|ab|, C=|a||b|, D=-ab$ ។

តាមករណីខាងក្រោម តើចំនួន $A,B,C$ និង $D$ ស្មើគ្នាដែរឬដែរ?

ក. $a$ និង $b$ មានសញ្ញាដូចគ្នា ។

ខ. $a$ និង $b$ មានសញ្ញាខុសគ្នា ។

13. ដោយប្រើសំរាយបញ្ជាក់តាមសំណើផ្ទុយពីរសម្មិតកម្មចូរបង្ហាញថា :

ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ បើ $n^2>25$ នោះ $n>5$ ។

14. ដោយប្រើសំរាយបញ្ជាក់តាមសំណើផ្ទុយពីការពិតបង្ហាញថា :

ក. $x+\frac{1}{x}>2$ ចំពោះគ្រប់ $x>1$ ។

ខ. គ្មានចំនួនគត់រ៉ឺឡាទីប $p$ និង $q$ ដែល

$\frac{p^2}{q^2}=2$ ។

15. គណនាផលបូក និងផលដកនៃចំនួនក្នុងប្រព័ន្ធគោល ដូចខាងក្រោម :

ក. $110_2+101_2$

ខ. $1011_2+101_2$

គ. $1101_2-1001_2$

16. $\Delta ABC$ ជាត្រីកោណកែងត្រង់កំពូល $B$ ហើយមានជ្រុង $AB=1$ ។ $D$ ជាចំណុចមួយនៅលើជ្រុង $BC$ ដែល $AD=CD=2$ ។

រកប្រវែងជ្រុង $AC$ ?

## ដំណោះស្រាយ

1) <u>សរសេរជាឃ្លា</u>

ក. $\overline{p}\wedge q$ : ចំនួនកើនឡើងនិងសិស្សភាគច្រើនចូលចិត្តរៀនភាសាខ្មែរ ។

ខ. $p\vee\overline{q}$ : ចំនួនសិស្សថយចុះរឺសិស្សភាគច្រើនមិនចូលចិត្តរៀនភាសារខ្មែរ ។

2) តាងសំណើ :

$p$ : ការសម្ភាសធ្វើការបានលទ្ធផលល្អ

$q$ : អ្នកនឹងបានការងារធ្វើ

គេមាន $\begin{Bmatrix} p\Rightarrow q \\ q \end{Bmatrix}$ ពិត , នោះ $\begin{Bmatrix} p \\ p \end{Bmatrix}$ អាចពិតឬមិនពិត

ដូចនេះ យើងមិនអាចសន្និដ្ឋានថាការសម្ភាសបានលទ្ធផលល្អទេ ។

3) ក. <u>កំណត់សំណុំរងតាមការរៀបរាប់ឈ្មោះធាតុ</u>

$A=\{2,4,6,8,10,12,14,16,18,20\}$

$B=\{3,6,9,12,15,18\}$

$C=\{6,12,18\}$

ខ. <u>កំណត់តម្លៃភាពពិតនៃសំណើនីមួយៗ</u> :

ក. $(C\subset A)=1$

ខ. $(B\subset A)=0$

គ. $(C\subset B)=1$

4) តាង ជាសំណុំចំនួនគត់ធម្មជាតិពី 1 ដល់ 100 ដែលជាពហុគុណនៃ 3 និង ពហុគុណនៃ 5

ដូចនេះ $A=\{15,30,45,60,75,90\}$

5) ក. $A=\{3,5,7,9,11,13,1517,19\}$

$B=\{3,5,7,11,13,17,19\}$

ខ. $C=A\cap B=\{3,5,7,11,13,17,19\}$

$D=A\cup B=\{3,5,7,9,11,13,15,17,19\}$

6) រកលក្ខខណ្ឌនៃសំណើ

ក. $p$ ពិត និង $q$ មិនពិត

ខ. $p$ មិនពិត និង $q$ មិនពិត

គ. $p$ និង $q$ មានតម្លៃភាពពិតខុសគ្នា

ឃ. $p$ និង $q$ មានតម្លៃភាពពិតខុសគ្នា ។

7) កំណត់តម្លៃភាពពិតនៃសំណើ

ដើម្បីកំណត់តម្លៃភាពពិតនៃសំណើទាំងនេះ យើងត្រូវសង់តារាងតម្លៃភាពពិតរបស់វា,ដូចនេះ

ក. ត.$\left(\left(p \vee \overline{q}\right) \wedge \left(\overline{p \wedge r}\right)\right) = 1$

ខ. ត.$\left(\left(\overline{r} \vee \overline{p}\right) \vee \overline{q}\right) = 1$

គ. ត.$\left(\left(\overline{p} \vee \overline{q}\right) \vee \left(\overline{r} \vee q\right)\right) = 1$

ឃ. ត.$\left(\left(\overline{r} \vee \overline{q}\right) \wedge \left(\overline{r} \vee \overline{p}\right)\right) = 0$

8) រកឧទាហរណ៍ផ្ទុយ :

ក. បើយក $k = 26$ នោះ $f(x) = 0$

យើងអាចសរសេរ : $f(x) = x^2 - 27x + 26 = 0$

មានរឹស ផ្សេងគ្នាគឺ $x_1 = 1, x_2 = 26$

មានន័យថា សមីការមានឬសតែពីរគត់

ខ. យក $n = 0 \Rightarrow f(x) = 6$

មិនចែកដាច់នឹង12 ទេ ។

9) ក. $G = \{1, 6, 7, 8\}$

$p = \{4, 5, 6, 7, 8\}$

ខ. $x = 1$

10) ក. $A = \{4, 5\}$

$B = \{5, 6, 7, 8\}$

ខ. $A \subseteq B$ ជាសំណើពិត

11)



តាង $U$ : សំណុំអបិតិជនទាំងអស់ដែលបានសម្ភាស

$A$ : សំណុំអបិតិជនដែលចូលចិត្តទិញអាវ

$B$ : សំណុំអបិតិជនដែលចូលចិត្តទិញខោ

$A \cap B$ : សំណុំអបិតិជនដែលចូលចិត្តទិញខោនិងអាវ

<u>រកចំនួនអបិតិជនដែលចូលចិត្ត</u>

ក. ទិញតែអាវគឺ :

$$n\left(A \cap \overline{B}\right) = n(A) - n(A \cap B)$$

$$= 90 - 41 = \boxed{49} \text{ នាក់}$$

ខ. ទិញតែខោគឺ:

$$n\left(B \cap \overline{A}\right) = n(B) - n(A \cap B)$$

$$= 50 - 41 = \boxed{9} \text{ នាក់}$$

គ. មិនទិញអ្វីសោះគឺ :

$$n\left(\overline{A \cup B}\right) = n(u) - n(A \cup B) \quad (1)$$

តែ $n(A \cup B) = n(A) + n(B) - n(A \cap B)$

$$= 90 + 50 - 41 = 99$$

(1) នោះគេបាន : $n(\overline{A\cup B})=145-99=$ **46** នាក់

12) $a,b\in \square^*, A=ab, B=|ab|,$

$C=|a|.|b|, D=-ab$ ។

ក. ករណី $a$ និង $b$ មានអញ្ញាតដូចគ្នា,

គេបាន: $a.b>0$

ម្យ៉ាងទៀត $|ab|=|a|.|b|=a.b\neq -ab$

ដូចនេះ $A=b=C\neq D$

ខ. $a$ និង $b$ មានអញ្ញាតខុសគ្នា នោះ $ab<0$

គេបាន : $|ab|=|a|.|b|=-ab\neq ab$

ដូចនេះ: $A\neq B=D=C$

13) ដោយប្រើសំរាយបញ្ជាក់សំណើផ្ទុយពីសម្មតិកម្ម

បង្ហាញថា : $\forall n\in \square$, បើ $n^2>25$ នោះ $n>5$.

តាង $p: n^2>25$

$q: n > 5$

ឧបមាថា : $\bar{q}: n \leq 5$ នោះគេបាន :

$$n = 1, 2, 3, 4, 5$$

$$n = 1 \Rightarrow n^2 = 1$$

$$n = 2 \Rightarrow n_2 = 4$$

ចំពោះ $n = 3 \Rightarrow n^2 = 9$

$$n = 4 \Rightarrow n^2 = 16$$

$$n = 5 \Rightarrow n^2 = 25$$

មានន័យថា $n^2 \leq 25$ ផ្ទុយពីសម្មតិកម្ម

គេបាន $\bar{q} \Rightarrow \bar{p}$ ជាសំណើពិត

ហើយ $p \Rightarrow q$ ជាសំណើពិតដែរ ។

ដូចនេះ បើ $n^2 > 25$ នោះ $n > 5, \forall n \in \square$ .

# មេរៀនទី1 ពហុធា

## មេរៀនសង្ខេប

*ឯកធា និង ពហុធា*

*+ឯកធា គឺជាកន្សោមដែលប្រមាណវិធីលើអថេរ មានតែវិធីគុណ និងស្វ័យគុណដែលមាននិទស្សន្ត គត់វិជ្ជមាន ឬសូន្យ ។*

*+ឯកធាដូចគ្នា គឺជាឯកធាដែលមានផ្នែកអថេរដូចគ្នា ។*

*+ដឺក្រេ នៃឯកធា ជាផលបូកនិទស្សន្តរបស់អថេរ នីមួយៗនៃឯកធា ។*

*+ពហុធា ជាផលបូកនៃច្រើនឯកធាខុសគ្នា ។*

*+ដឺក្រេ នៃពហុធា គឺជាដឺក្រេរបស់តួដែលមានដឺក្រេ ខ្ពស់ជាងគេ ។*

## ប្រមាណវិធីលើពហុធា

+ដើម្បីបូក ឬដកពីរពហុធា គេត្រូវបូក ឬដកឯកធាដែលដូចគ្នា

+ដើម្បីគុណពហុធា និងពហុធាគេយកតួទីមួយៗនៃពហុធាទីមួយ គុណនិងគ្រប់តួនៃពហុធាទីពីរ រួចធ្វើប្រមាណវិធី ។

**រូបមន្ត**

$$(a+b)^2 = a^2 + 2ab + b^2$$

$$(a-b)^2 = a^2 - 2ab + b^2$$

$$(a-b)(a+b) = a^2 - b^2$$

$$(a+b+c)^2 = a^2 + b^2 + c^2 + 2ab + 2bc + 2ac$$

ចំណុច $P$ កណ្តាល $AB$ គឺ $p\left(\frac{x_a+x_b}{2},\frac{y_a+y_b}{2}\right)$ ។

កូអរដោនេនៃចំណុចចែកក្រៅនៃអង្កត់មួយក្នុងតម្រុយ

កូអរដោនេ $Q\left(\frac{mx_a-nx_a}{m-m},\frac{my_b-ny_a}{m-n}\right)$ ។

## លំហាត់

1. *គេឲ្យចំណុច* $A(-3), B(2), C(5)$ *និង* $D\left(-\frac{3}{2}\right)$ *នៅលើបន្ទាត់ចំនួនពិត ។*

   ក. *ដៅចំណុច* $A, B, C$ *និង* $D$ *។*

   ខ. *កំណត់ចម្ងាយ* $AO, AB, BC$ *និង* $DC$ *។*

2. *គេឲ្យពីរចំណុច* $A(-3)$ *និង* $B(8)$ *។ តាង* $P$ *ជាចំណុចក្នុងនៃ* $AB$ *តាមផលធៀប* $2:3$ *ហើយ* $Q$ *ជាចំណុចចែកក្រៅនៃអង្កត់* $AB$ *តាមផលធៀប* $4:3$ *។ រកកូអរដោនេនៃចំណុចកណ្តាល* $M$ *នៃអង្កត់* $PQ$ *។*

3. *គេឲ្យពីរចំណុច* $E(2)$ *និង* $F(6)$ *។ តាង* $D$ *ជាចំណុចចែកក្នុងនៃ* $EF$ *តាមផលធៀប* $4:3$ *និង* $G$ *ជាចំណុចចែកក្រៅនៃ* $EF$ *តាមផលធៀប* $1:3$ *។ ចូររកប្រវែង* $DG$ *។*

4. *គេឲ្យត្រីកោណមួយ ដែលកំពូល* $A(-2,4), B(0,9)$ *និង* $C(3,2)$ *។ តើត្រីកោណនេះជាត្រីកោណកែងឬទេ?*

5. *រកកូអរដោនេនៃកំពូលទាំងបីនៃត្រីកោណ ដែលចំណុច*

កណ្តាលនៃជ្រុងគឺ $(-2,3),(3,-1)$ និង $(5,4)$ ។

6. រកកូអរដោនេនៃកំពូល $D$ នៃចតុកោណកែង $ABCD$ បើកូអរដោនេនៃកំពូល $A(0,0),(0,5)$ និង $C(8,0)$ រួចគណនាផ្ទៃក្រឡាវា ។

7. រកកូអរដោនេនៃកំពូល $D$ នៃប្រលេឡូក្រាម $ABCD$ បើកូអរដោនេនៃកំពូល $A(-2,5),B(4,3)$ និង $C(-2,3)$ ។

8. រកកូអរដោនេនៃចំណុច $E$ ចែកក្នុង និង $F$ ចែកក្រៅនៃអង្កត់ $AB$ តាមផលធៀប $2:3$ ចំពោះគូចំណុច $A(1,3)$, $B(-2,5)$ រួចរកប្រវែង $EF$ ។

## ដំណោះស្រាយ

1. ក.




ខ. $AO=3, AB=5, BC=3, DC=6,5$

2.



ដោយ $P$ ជាចំណុចចែកក្នុងនៃ $AB$ តាមផលធៀប $2:3$

គេបាន៖ $\left(\frac{AP}{PB}=\frac{m}{n}\right)$ នោះ $\frac{P-(-3)}{8-P}=\frac{2}{3}$ នោះ $P=\frac{7}{5}$

ហើយ $Q$ ជាចំណុចចែកក្រៅនៃអង្កត់ $AB$ តាមផលធៀប

$4:3\ \frac{AQ}{QB}=\frac{4}{3}$ នោះ $\frac{y+3}{y-8}=\frac{4}{3}$ នោះ $y=41$ កូអរដោនេនៃ

ចំណុចកណ្ដាល $M$ នៃអង្កត់ $PQ$ គឺ $\frac{4+\frac{7}{5}}{2}=21.23$

3.




$D$ ជាចំណុចចែកក្នុងនៃ $EF$ តាមផលធៀប $4:3$

$\frac{ED}{DF}=\frac{3}{4}$ នោះ $\frac{x-2}{6-x}=\frac{4}{3}$ នោះ $x=\frac{30}{7}$

$G$ ជាចំណុចចែកក្រៅនៃ $EF$ តាមផលធៀប $1:3$

$\frac{EG}{FG}=\frac{1}{3}$ នោះ $\frac{y-2}{y-6}=\frac{1}{3}$ នោះ $y=0$ ប្រវែង

$DG=\dfrac{30}{7}$ (ឯកតាប្រវែង)

4. $AB\left(0-(-2),9-4\right), AB\left(2,5\right)$

នោះ $AB=\sqrt{2^2+5^2}=\sqrt{29}$ នោះ $AB^2=29$

$AC\left(3-(-2),2-9\right), AC\left(5,-2\right)$

នោះ $AC=\sqrt{5^2+(-2)^2}=\sqrt{29}$ នោះ $AC^2=29$

នោះ $BC=\sqrt{3^2+(-7)^2}=\sqrt{29}$ នោះ $BC^2=58$

យើងឃើញថា $AB^2+AC^2+BC^2$

តាមទ្រឹស្តីបទពីតាគ័រ ត្រីកោណ $ABC$ កែងត្រង់ $A$ ។

5. យក $A(-2,3), B(3,-1)$ និង $C(5,4)$

កូអរដោនេនៃ $I$ កណ្ដាល $AB$ គឺ $I\left(\dfrac{-2+3}{2},\dfrac{3-1}{2}\right)$

នោះ $I\left(\dfrac{1}{2},1\right)$

កូអរដោនេនៃ $J$ កណ្ដាល $AC$ គឺ $J\left(\dfrac{-2+5}{2},\dfrac{3+4}{2}\right)$

នោះ $J\left(\dfrac{3}{2},\dfrac{7}{2}\right)$

កូអរដោនេនៃ $K$ កណ្ដាល $CB$ គឺ $K\left(\frac{3+5}{2},\frac{4-1}{2}\right)$

នោះ $K\left(4,\frac{3}{2}\right)$

6. កូអរដោនេនៃកំពូល $D$ នៃចតុកោណកែង $ABCD$

គឺ $D(8,5)$ ក្រឡាផ្ទៃ $ABCD$ គឺ $5\times 8=40$ (ឯកតាផ្ទៃ) ។

7. កូអរដោនេនៃកំពូល $D(x,y)$ នៃប្រលេឡូក្រាម $ABCD$

គេបាន $\overrightarrow{CD}=\overrightarrow{AB}$

$(x+2,y+3)=(-2-4,5-3)$

នោះ $\begin{cases}x+2=-6\\ y+3=2\end{cases}$ នោះ $\begin{cases}x=-8\\ y=1\end{cases}$

ដូចនេះកូអរដោនេនៃកំពូល $D(-8,-1)$ ។

8. បើ $E(x,y)$ ចែកអង្គ $AB$ ខាងក្នុងតាមផលធៀប $2:3$ ។

កូអរដោនេនៃចំណុច $E\left(\frac{nx_a+mx_b}{m+n},\frac{ny_a+my_b}{m+n}\right)$

$E\left(\frac{3.1+2.(-2)}{2+3},\frac{3.3+2.5}{2+3}\right)$

$$E\left(-\frac{1}{5},\frac{19}{5}\right)$$

*បើ* $F(x,y)$ *ចែកអង្គ* $AB$ *ខាងក្រៅតាមផលធៀប* 2 : 3 ។

*កូអរដោនេនៃចំណុច* $F\left(\frac{2.(-2)-3.1}{2-3},\frac{2.5-3.3}{2-3}\right)$

$$F(7,-1)$$

*កូអរដោនេនៃ* $EF\left(7+\frac{1}{5};-1-\frac{19}{5}\right)$

$$EF\left(\frac{36}{5},\frac{24}{5}\right)$$

*នោះ* $EF=\sqrt{\left(\frac{36}{5}\right)^2+\left(\frac{24}{5}\right)^2}=\frac{\sqrt{1872}}{5}=8.65$

(ឯកតាប្រវែង) ។

# មេរៀនទី2 សមីការបន្ទាត់

## មេរៀនសង្ខេប

1. បន្ទាត់ $y = mx + n$ និង $y = m'x + n'$ បន្ទាត់ទាំងពីរស្របគ្នា លុះត្រាតែ $m = m'$ បន្ទាត់ទាំងពីរស្របគ្នា លុះត្រាតែ $m.m' = -1$

2. សមីការបន្ទាត់កាត់ចំណុច $(x_1, y_1)$ មានមេគុណប្រាប់ទិស $m$ គឺ $y - y_1 = m(x - x_1)$

មីការនៃបន្ទាត់កាត់តាមពីរចំណុច $(x_1, y_1)$ និង

) គឺ $y - y_1 = \frac{y_2 - y_1}{x_2 - x_1}(x - x_1)$

4. ចម្ងាយ $d$ រវាងចំណុច $(x_1, y_1)$ និងបន្ទាត់ $ax + by + c = 0$ គឺ $d = \frac{|ax_1 + by_1 + c|}{\sqrt{a^2 + b^2}}$

## លំហាត់

1. រកសមីការបន្ទាត់កាត់តាមចំណុច $A(2,5)$ មានមេគុណប្រាប់ទិស ស្របតាមបន្ទាត់ពីរចំណុច $B(-5,3)$ និង $C(2,-1)$ ។

2. រកសមីការបន្ទាត់កាត់តាមចំណុច $A(3,1)$ ស្របទៅ និងបន្ទាត់ $L: 2x-3y-5=0$ ។

3. រកសមីការបន្ទាត់កាត់តាមចំណុច $B(-1,1)$ កែងទៅនិងបន្ទាត់ $L: x+3y+4=0$ ។

4. បង្ហាញថាបន្ទាត់កាត់តាមពីរចំណុច $A(a,0)$ និង $(0,b)$ មានសមីការ $\frac{x}{a}+\frac{y}{b}=1$ សន្មត $ab \neq 0$ ។

5. ក្នុងប្លង់គូអរដោនេគេមានចំណុច $A(1,-3), B(2,-1)$ និងបន្ទាត់ $D: y=x-2$ ។

   ក. រកសមីការបន្ទាត់ $AB$ ។

   ខ. កំណត់សមីការបន្ទាត់ $L$ ស្របនឹងបន្ទាត់ $AB$ កាត់គល់ $O$ ។

គ. គណនាកូអរដោនេចំណុចប្រសព្វ $I$ នៃបន្ទាត់ $D$ និង $L$ ។

6. រកសមីការបន្ទាត់ដែលកាត់តាមចំនុចគល់ និងកាត់តាមចំណុចប្រសព្វរវាងបន្ទាត់ $L_1 : 2x - y - 1 = 0$ និង $L_1 : x + 2y - 2 = 0$ ។

7. តាង $B$ និង $C$ ជាចំណោលកែងនៃ $O$ និង $A(13,0)$ រៀងគ្នាទៅលើបន្ទាត់ $5x - 12y + 65 = 0$ ។

គណនាក្រឡាផ្ទៃចតុកោណព្នាយ $OACB$ ។



8. បង្ហាញថាកម្ពស់ ឬបន្ទាយកម្ពស់ទាំងបីនៃត្រីកោណមួយប្រសព្វគ្នាត្រង់ចំណុច ។

9. គេមានបន្ទាត់ $D: y = 2x + 3$ និងចំណុច $A(5,1)$ ជាចំណុចនង់ដែលមិននៅលើបន្ទាត់ $D$ ។ រកសំណុំចំណុចនៃចំណុច $Q$ កណ្ដាលអង្កត់ $AP$ ពេលដែលចំណុច $P$ ផ្លាស់ទីលើបន្ទាត់ $D$ ។

10. រកសំណុំចំណុចដែលមមានផលធៀបចម្ងាយ $O$ និង $A(3,0)$ ស្មើ $2:1$ ។

## ដំណោះស្រាយ

1. មេគុណប្រាប់ទិសនៃបន្ទាត់ គឺ បន្ទាត់ $L'$

$$a = \frac{3-(-1)}{-5-2} = -\frac{4}{7}$$

បន្ទាត់ $L$ មានរាង៖

$y = a'x + b$ ដោយ $L \square L'$ នោះ $a' = -\frac{4}{7}$

ដូចច្នេះបន្ទាត់ $L: y = -\frac{4}{7}x + \frac{43}{7}$

2. បន្ទាត់ $D: y = ax + b$ ដោយ $D \square L$ នោះ $a = \frac{2}{3}$

ដូចេ្នះ បន្ទាត់ $D: y = \frac{2}{3}x - 1$

3. បន្ទាត់ $D: y = 3x - 8$ ។

4. បន្ទាត់កាត់តាមពីរចំណុច $A(a,0)$ និង $B(0.b)$

សមីការ ដោយ $\frac{y-0}{x-a} = \frac{b-0}{0-a} \Leftrightarrow ay + bx = ab$

ដោយ $ab \neq 0$ គេបាន $\frac{x}{a} + \frac{y}{b} = 1$

5. ក. $AB: y = 2x + 5$

ខ. $L: y = 2x$

គ. បន្ទាត់ $D$ និង $L$ ប្រសពគ្នាត្រង់ $I(-2,-4)$ ។

6. បន្ទាត់ $L_1$ និង $L_2$ ប្រសពគ្នាត្រង់ $\left(\frac{4}{5}, \frac{3}{5}\right)$

បន្ទាត់ $L: y = ax$ កាត់តាមចំណុច $\left(\frac{4}{5}, \frac{3}{5}\right)$

នោះ $\frac{3}{5} = \frac{4}{5}(a \Rightarrow a) = \frac{3}{4}$

ដូចនេះបន្ទាត់ $L: y=\frac{3}{4}x$ ។

7. ចំងាយ $|OB|=\frac{65}{13}=5$ , $|AC|=10$

$$B\left(x=-\frac{25}{13}, y=\frac{60}{13}\right) , \ C\left(x=\frac{119}{13}, y=\frac{120}{13}\right)$$

$$BC=12 \ , \ S=\frac{(5+10)12}{2}=90$$

8. តាងបន្ទាត់ $BC$ ជាអ័ក្សអាប់ស៊ីស, បន្ទាត់កែង $AO$ ពី $A$ ទៅ $BC$ ជាអ័ក្សអរដោនេ និង $O$ ជាគល់តំរុយ នោះគេបានកូអរដោនេកំពល $A(0,a), B(b,0), C(c,0)$ ។ $(i)$ បើ $b\neq 0$ និង $c\neq 0$ សមីការបន្ទាត់ $CM$ ពី $C$ កែងជ្រុង

$AC$ គឺ $y=\frac{b}{a}(x-a)=\frac{b}{a}x-\frac{bc}{a}$

សមីការបន្ទាត់ $BN$ ពី $B$ ទៅកែងជ្រុង $AC$ គឺ

$y=\frac{c}{a}(x-c)=\frac{c}{a}x-\frac{bc}{a}$

$MC$ និង $BN$ កាត់តាមគ្នាត្រង់ចំណុច $\left(0,-\frac{bc}{a}\right)$ នៅ

*ស័ក្សអរដោនេ ។*

*ដូចេ្នះ បន្ទាត់ទាំងបីកាត់គ្នាត្រង់មួយចំណុចនៅលើបន្ទាត់ កែងបីស្របគ្នាត្រង់កំពូលមុំកែង ។ ចំណុចប្រសព្វបន្ទាត់ទាំងបី នេះហៅថា អរត្វូសង់នៃ $\Delta ABC$ ។*

# មេរៀនទី 3 ធរណីមាត្រក្នុងប្លង់

## មេរៀនសង្ខេប

1. សមីការស្តង់ដានៃរង្វង់ដែលមានផ្ចិត $I(a,b)$ និងកាំ $r$ គឺ $(x-a)^2+(y-b)^2=r^2$
2. រង្វង់ដែលមានផ្ចិតជាគល់តំរុយ $O(0,0)$ និងកាំ $r$ មានសមីការស្តង់ដា $x^2+y^2=r^2$ ។
3. សមីការទូទៅនៃរង្វង់គឺ $x^2+y^2+Ax+Bx+C=0$
4. សមីការនៃបន្ទាត់ប៉ះនៃរង្វង់ $x^2+y^2=r^2$ ត្រង់ចំណុច $(x_0,y_0)$ គឺ $x_0x+y_0y=r^2$
5. គេឲ្យសមីការរង្វង់ $(x-a)^2+(y-b)^2=r^2$ និងបន្ទាត់ $D: y=mx+n$ នោះគេបាន

$$(x-a)^2+\left[(mx+n)^2-b\right]^2=r^2 \quad (1)$$

បើ $\Delta$ ជាឌីសគ្រីមីណង់នៃសមីការ $(1)$ គេបាន

ក. បើ $\Delta>0$ នោះបន្ទាត់ និងរង្វង់ប្រសព្វគ្នាត្រង់ពីរចំណុច

ខ. បើ $\Delta = 0$ នោះបន្ទាត់ប៉ះនឹងរង្វង់

គ. បើ $\Delta < 0$ នោះបន្ទាត់ និងរង្វង់មិនប្រសព្វគ្នាទេ

**ចំណេះដឹងបន្ថែម**

សមីការនៃបន្ទាត់ប៉ះរង្វង់ $(x-a)^2+(y-b)^2=r^2$ ត្រង់ចំណុច $(x_0,y_0)$ គឺ $(x_0-a)(x-a)+(y_0-b)(y-b)=r^2$

## លំហាត់

1. សរសេរសមីការរង្វង់ជាទំរង់ស្តង់ដា $(x-a)^2+(y-b)^2=r^2$ ដោយស្គាល់ផ្ចិត $I$ និងកាំ $r$ ក្នុងករណីខាងក្រោម៖

   ក. $I(0,0)$ , $r=1$

   ខ. $I(0,1)$ , $r=\sqrt{2}$

   គ. $I(2,0)$ , $r=\sqrt{3}$

   ឃ. $I(1,1)$ , $r=2$

   ង. $I(-1,3)$ , $r=2$

   ច. $I(-2,-2)$ , $r=3$

2. កំណត់ផ្ចិត និងកាំនៃរង្វង់ដែលមានសមីការស្តង់ដាដូចខាងក្រោម៖

ក. $x^2+y^2=9$

ខ. $(x-2)^2+(y-1)^2=16$

គ. $(x-1)^2+(y+2)^2=25$

ឃ. $x^2+(y-1)^2=36$

3. កំណត់ផ្ចិត និងកាំនៃរង្វង់ដែលមានសមីការស្តង់ដាដូចខាងក្រោម៖

ក. $x^2+y^2+4x=6$

ខ. $x^2+y^2-6x+2y=6$

គ. $2x^2+2y^2-2x+2y=1$

ឃ. $3x^2+3y^2-2x-3y+1=0$

4. សរសេរសមីការទូទៅ $x^2+y^2-4x+2y+4=0$ ជាទំរង់សមីការស្តង់ដា $(x-a)^2+(y-b)^2=r^2$ រួចសង់ក្រាប ។

5. សរសេរសមីការទូទៅ $2x^2+2y^2-8x=0$ ជាទំរង់

សមីការស្តង់ដា $(x-a)^2+(y-b)^2=r^2$

រូបសង់ក្រាប ។

6. រកសមីការរង្វង់ទូទៅកាត់តាមបីចំណុចខាងក្រោម៖

ក. $(1,0),(0,1)$ និង $(3,4)$

ខ. $(2,2),(-2,1)$ និង $(2,3)$

7. រកសមីការនៃរង្វង់ខាងក្រោម៖

ក. រង្វង់ដែលមានផ្ចិត $I(2,1)$ និងកាត់តាមចំណុច $A(-1,3)$ ។

ខ. រង្វង់ដែលកាត់តាមចំណុច $C(3,\sqrt{3})$ និង $D(2,-2)$ ហើយមានផ្ចិតនៅលើអ័ក្សអាប់ស៊ីស ។

គ. រង្វង់ដែលកាត់តាមចំណុច $E(1,2)$ ហើយប៉ះទៅអ័ក្សកូអរដោនេទាំងពីរ ។

8. គេឲ្យបីចំណុច $A(0,0),B(4,2)$ និង $C(5,1)$ ។ រកសំណុំចំណុចនៃចំណុច $P$ ដែលផ្ទៀងផ្ទាត់ $AP^2+BP^2+CP^2=49$ ។

9. គេមានចំណុច $A(5,4)$ នៅលើរង្វង់

$(x-2)^2+(y-3)^2=10$ ។ រកសមីការបន្ទាត់ប៉ះរង្វង់ត្រង់ចំណុចនេះ ។

10. រកសមីការបន្ទាត់ប៉ះត្រង់ចំណុច $A(3,4)$ ទៅនឹងរង្វង់ $x^2+y^2=25$ ។

11. រកសមីការបន្ទាត់ប៉ះគូសចេញពីចំណុច $B(0,-2)$ ប៉ះទៅរង្វង់ $x^2+y^2=1$ ។

12. គេមានសមីការរង្វង់ $x^2+y^2=13$ និងបន្ទាត់ $x+5y=13$ មានចំណុចប្រសព្វពីរផ្សេងគ្នា ។ រកកូអរដោនេនៃចំណុចប្រសព្វទាំងនេះ ។

13. គេមានសមីការរង្វង់ $x^2+y^2=1$ និង $y=mx+2$ ដែល $m$ ជាប៉ារ៉ាម៉ែត្រ ។ សិក្សា $m$ ចំនួននៃចំណុចប្រសព្វរវាងបន្ទាត់ និងរង្វង់ ។

14. រកសមីការនៃរង្វង់ដែលកាត់តាមចំណុច $O(0,0)$, $A(1,2)$ និង $B(4,3)$ ។

15. រកសមីការនៃរង្វង់ដែលកាត់តាមចំណុច $A(1,3)$, $B(2,0)$ និង $C(-1,-1)$ ហើយរកកូអរដោនេនៃផ្ចិត និងប្រវែងកាំរបស់វា ។

16. គេឲ្យបណ្ដុំចំណុចបី $A(1,0), B(-2,-3)$ និង $C(-5,-3)$ ។ រកសំណុំចំណុច $P$ ដែលផ្ទៀងផ្ទាត់

$AP^2 = BP^2 + CP^2$

17. គេមានបន្ទាត់ $3y = x + 5$ និងរង្វង់

$x^2 + y^2 - 6x - 2y - 15 = 0$ ។

ក. បង្ហាញថាបន្ទាត់កាត់រង្វង់ត្រង់ពីរចំណុចផ្សេងគ្នា ។

ខ. រកកូអរដោនេនៃចំណុចប្រសព្វរវាងបន្ទាត់ និងរង្វង់នោះ ។

គ. គណនាចំងាយរវាងពីរចំណុចប្រសព្វនេះ ។

18. បង្ហាញថាបន្ទាត់ $y = 3x + 5$ កាត់រង្វង់

$x^2 + y^2 - 2x - 6y + 5 = 0$ តាមអង្កត់ធ្នូមួយ និងគណនាប្រវែងអង្កត់ធ្នូនេះ ។

19. បង្ហាញថារង្វង់ $x^2 + y^2 - 2y - 4 = 0$ និង

$x^2 + y^2 - x + y - 12 = 0$ ប្រសព្វគ្នាត្រង់ពីរចំណុចផ្សេងគ្នា និងរកសមីការនៃអង្កត់ធ្នូរួមនោះ ។

20. បង្ហាញថារង្វង់ $x^2 + y^2 + 2x - 8y + 5 = 0$ និង

$x^2 + y^2 - 4x - 4y + 7 = 0$ អរតូកូណាល់គ្នា ។

## ដំណោះស្រាយ

1. *សរសេរសមីការរង្វង់ជាទំរង់ស្តង់ដា*

*ទំរង់ស្តង់ដានៃសមីការរង្វង់គឺ៖*

$(x-a)^2+(y-b)^2=r^2$ មានផ្ចិត $I(a,b)$ និងកាំ $r$

ក. $x^2+y^2=1$

ខ. $x^2+(y-1)^2=2$

គ. $(x-2)^2+y^2=3$

ឃ. $(x-1)^2+(y-1)^2=2$

ង. $(x+1)^2+(y+2)^2=4$

ច. $(x+2)^2+(y+2)^2=9$

2. *កំណត់ និងកាំនៃរង្វង់*

*តាមរូបមន្តសមីការស្តង់ដានៃសមីការរង្វង់*

$(x-a)^2+(y-b)^2=r^2$ *ដែលមានផ្ចិត* $I(a;b)$ *និងកាំ* $r$ ។

*ដូចនេះគេបាន៖*

ក. *ផ្ចិត* $I(0,0)$ *កាំ* $r=3$

ខ. ផ្ចិត $I(2,1)$ កាំ $r=4$

គ. ផ្ចិត $I(1,-2)$ កាំ $r=5$

ឃ. ផ្ចិត $I(0,1)$ កាំ $r=6$

3. <u>កំណត់ផ្ចិត និងកាំរង្វង់៖</u>

ពិនិត្យមើលលំហាត់ពី "ក" ដល់ "ឃ" គេឲ្យឃើញនូវសមីការទូទៅនៃរង្វង់គឺ

$$x^2+y^2+Ax+By+C=0$$

ដែលយើងត្រូវបំលែងទៅជា

ទំរង់ស្តង់ដា $(x-a)^2+(y-b)^2=r^2$ ដែលមានផ្ចិត $I(a,b)$ និងកាំ $r$ ដែលយើងត្រូវរក ។

<u>ឧទាហរណ៍៖</u>

$$x^2+y^2+4x=6$$

$$\Leftrightarrow \left(x^2+2.2.x+2^2\right)+\left(y^2+2.y.0+0^2\right)-2^2=6$$

$$\Leftrightarrow \left(x+2\right)^2+\left(y+0\right)^2=\sqrt{10}^2$$

$$\Rightarrow I(-2;0)\;\&\; r=\sqrt{10}$$

ដូចនេះ

ក. ផ្ចិត $I(-2,0)$ កាំ $r=\sqrt{10}$

ខ. ផ្ចិត $I(3,-1)$ កាំ $r=4$

គ. ផ្ចិត $I(\frac{1}{2},\frac{1}{2})$ កាំ $r=1$

ឃ. ផ្ចិត $I(\frac{1}{3},\frac{1}{2})$ កាំ $r=\frac{1}{6}$

4. <u>សរសេរសមីការទំរង់ទូទៅជាទំរង់ដា៖</u>

មាន $x^2+y^2-4x+2y+4=0$

$$\left(x^2-2.2.x+2^2\right)+\left(y^2+2.y.1+1\right)^2-2^2-1+4=0$$

$$(x-2)^2+(y+1)^2=1^2$$

ដូចនេះ $\boxed{(x-2)^2+(y+1)^2=1}$

5. $\boxed{(x-2)^2+(y+0)^2=2^2}$

6. <u>រកសមីការរង្វង់ទទៅកាត់តាមបីចំណុច</u>

សមីការរង្វង់ទូទៅមានរាង៖

$$x^2+y^2+Ax+By+c=0$$

ក. កាត់តាមចំណុច

★ $(1,0)$ នោះ៖ $1+0+A+0+C=0$

$A+C=-1 \qquad (1)$

★ $(0;1)$ នោះ៖ $0+1+0+B+C=0$

$B+C=-1 \qquad (2)$

★ $(3;4)$ នោះ៖ $9+16+3A+4B+C=0$

$3A+4B+C=-25 \quad (3)$

តាម $(1),(2)$ និង $(3)$ យើងបាន៖

$$\begin{cases} A+C=-1 & (1) \\ B+C=-1 & (2) \\ 3A+4B+C=-25 & (3) \end{cases}$$

★ យក $(3)-(1): 2A+4B=-24$

$\Rightarrow A+2B=-12 \quad (4)$

★ យក $(3)-(2): 3A+3B=-24$

$\Rightarrow A+B=-8 \qquad (5)$

★ យក $(4)-(5): B=-4$

$\Rightarrow A=-8-B=-8+4=-4$

$\Rightarrow C=-1-A=-1+4=3$

ដូចនេះ៖ $\boxed{(C)..x^2+y^2-4x-4y+3=0}$

ខ. ធ្វើរបៀបដូចគ្នា

ដូចនេះ $\boxed{(C): x^2+y^2+\frac{1}{2}x-5y+1=0}$

7. <u>រកសមីការរង្វង់</u>

ក. សមីការរង្វង់ត្រូវរករាង $(x-a)^2+(y-b)^2=r^2$

មានផ្ចិត $I(2,1); A(-1,3)$

$$\Rightarrow (x-2)^2+(y-1)^2=r^2$$

ដោយ $r=IA \Rightarrow r^2=IA^2$

$$\Rightarrow r^2=(x_A-x_I)^2+(y_A-y_I)^2$$

$$=(-1-2)^2+(3-1)^2$$

$$=9+4=13$$

ដូចនេះ $\boxed{(C): (x-2)^2+(y-1)^2=\left(\sqrt{13}\right)^2}$

ខ. $\begin{cases}(a+4)^2+(y-b)^2=r^2\\(4-x)^2+(5-b)^2=r^2\\2a-b=1\end{cases}$

នោះ $a=1, b=1, r^2=25$ គេបាន

$$(x-1)^2+(y-1)^2=25$$

គ. យកផ្ចិត $I(a,a)$ នោះ:

$$(1-a)^2+(2-a)^2=a^2 \text{ គេបាន } a=1,\ a=5$$

ដូចនេះ: $(x-1)^2+(y-1)^2=1$

ឬ $(x-5)^2+(y-5)^2=25$

8. តាងកូអរដោនេនៃចំណុច $P(x,y)$

គេបាន $AP^2=x^2+y^2$

$BP^2=(x-4)^2+(y-2)^2$

និង $CP^2=(x-5)^2+(y-1)^2$

នោះ៖ $AP^2+BP^2+CP^2=49$

$$\Leftrightarrow x^2+y^2-6x-2y-1=0$$

រៀបសមីការនេះឡើងវិញគេបាន $(x-3)^3+(y-1)^2=11$

ដូច្នេះ សំណុំចំណុចនៃ $P$ ជារង្វង់ដែលមានកាំស្មើ $\sqrt{11}$

និងផ្ចិត $(3,1)$

9. សមីការបន្ទាត់ប៉ះរង្វង់ $3x+y-19=0$

10. សមីការបន្ទាត់ប៉ះរង្វង់ $3x+y-25=0$

11. សមីការបន្ទាត់ប៉ះរង្វង់ $y=\sqrt{3x}-2$ ឬ $y=-\sqrt{3x}-2$

12. បន្ទាត់ និងរង្វង់ប្រសព្វគ្នាត្រង់ចំណុច $(2,3)$ និង $(-2,3)$

13. ចំពោះ $m<-\sqrt{3}, m>\sqrt{3}$ នោះបន្ទាត់ប៉ះជារង្វង់ត្រង់ពីរចំណុចផ្សេងគ្នា ។

ចំពោះ $m=-\sqrt{3}, m=\sqrt{3}$ នោះបន្ទាត់ប៉ះជារង្វង់ត្រង់មួយចំណុច ។

ចំពោះ $-\sqrt{3}<m<\sqrt{3}$ នោះបន្ទាត់មិនកាត់រង្វង់ទេ ។

14. សមីការនៃរង្វង់ $x^2+y^2-7x+y=0$ ។

15. សមីការនៃរង្វង់ $x^2+y^2-2x-4=0$ ,

$$(x-0)^2+(y-1)^2=\left(\sqrt{5}\right)^2$$

ដូចនេះ សមីការនៃរង្វង់មានផ្ចិត $I(0,1)$ និងកាំ $r=\sqrt{5}$ ។

16. សំណុំចំណុចនៃចំណុច $P$ គឺជារង្វង់ដែលមានផ្ចិត $I(-8,-6)$ និងកាំ $r=3\sqrt{6}$ ។

17. ក. យក $x=3y-5$ ជំនួសក្នុងសមីការរង្វង់គេបាន $y^2-5y+4=0$ មាន $\Delta=9>0$

ដូចនេះ បន្ទាត់កាត់រង្វង់ ត្រង់ពីរចំណុចផ្សេងគ្នា ។

ខ. បន្ទាត់កាត់រង្វង់ត្រង់ $A(7,1)$ និង $B(-2,4)$

គ. $AB=3\sqrt{10}$ (ឯកតាប្រវែង)

18. យក $y=3x+5$ ជំនួសក្នុងរង្វង់ គេបាន $x^2+x=0$

បន្ទាត់កាត់រង្វង់ត្រង់ $A(0,5)$ និង $B(-1,2)$ ។

បន្ទាត់កាត់រង្វង់តាមអង្កត់ធ្នូ $AB=\sqrt{10}$ (ឯកត្តាប្រវែង) ។

19. $x^2+y^2-2y-4-\left(x^2+y^2-x+y-12\right)=0$

$\Leftrightarrow x-3y+8=0$ នេះគឺជាសមីការបន្ទាត់កាត់រង្វង់ត្រង់ពីរចំណុចផ្សេងគ្នាគឺ $A(-2,2)$ និង $(1,3)$ ។

20. $x^2+y^2+2x-8y+5=0$

$0\Leftrightarrow(x+1)^2+(y-4)^2=12$

ជារង្វង់ដែលមានផ្ចិត $I(-1,4)$ និងកាំស្មើ $r_1=\sqrt{12}$

$x^2+y^2-4x-4y+7=0\Leftrightarrow(x-2)^2+(y-2)^2=1$

ជារង្វង់ដែលមានផ្ចិត $J(2,2)$ និងកាំស្មើ $r_2=1$

នោះ $r_1^2+r_2^2=13$ ហើយ $d=IJ$

ដែល $d^2=IJ^2=\left(2-(1)^2\right)+(2-4)^2$

នោះ $d^2 = r_1^2 + r_2^2$

នេះបញ្ជាក់ថា រង្វង់ $x^2 + y^2 + 2x - 8y + 5 = 0$ និង

$x^2 + y^2 - 4x - 4y + 7 = 0$ អរតូកូណាល់គ្នា ។

# មេរៀនទី4

## ដោះស្រាយវិសមីការតាមក្រាប

### មេរៀនសង្ខេប

*របៀបដោះស្រាយវិសមីការតាមក្រាប គេត្រូវ:*

1. *សង់ក្រាបតាងសមីការនីមួយៗ ។*
2. *តាមក្រាបកំណត់តំបន់ចម្លើយវិសមីការនីមួយៗ ។*

*របៀបដោះស្រាយប្រព័ន្ធវិសមីការតាមក្រាប គេត្រូវ:*

1. *សង់ក្រាបតាងសមីការនីមួយៗ ។*
2. *តាមក្រាបកំណត់តំបន់ចម្លើយវិសមីការនីមួយៗ ។*
3. *យកតំបន់ចម្លើយរួមជាចម្លើយនៃប្រព័ន្ធវិសមីការ ។*

### លំហាត់

1. *ដោះស្រាយវិសមីការ*

*និងប្រព័ន្ធវិសមីការខាងក្រោមតាមក្រាប:*

*ក.* $x+2y-4>0$

ខ. $1 < x^2 + y^2 < 4$

គ. $x^2 + y^2 \leq 2x + 3$

ឃ. $x^2 + y^2 < 9,\ x + y > 2$

ង. $0 < x < 1\ ,0 < y < 1\ ,\ x^2 + y^2 > 1$

2. ក. សង់បន្ទាត់ $D : y = -x + 2$ និង

$D' = x - 2y - 2 = 0$ ក្នុងតំរុយតែមួយៗ

ខ. ទាញរកគូរចម្លើយប្រព័ន្ធសមិការតាមក្រាភិច

$$\begin{cases} y = -x + 2 \\ x - 2y - 2 = 0 \end{cases}$$

3. ដោះស្រាយប្រព័ន្ធវិសមីការខាងក្រោម :

ក. $\begin{cases} x + 4 < 0 \\ y \geq x - 2 \\ y < 2 \end{cases}$

ខ. $\begin{cases} 4x + 3y + 6 \geq 0 \\ y \geq 2x - 5 \\ 3x - 4y \geq 0 \end{cases}$

## ដំណោះស្រាយ

1. ក. វិសមីការមានតំបន់ចំលើយជាកន្ទះប្លង់ដែលគូសធូតបិតនៅខាងលើបន្ទាត់ព្រំដែន ។

ខ. វិសមីការមានតំបន់ចំលើយស្ថិតនៅក្នុង និងលើរង្វង់ផ្ចិត $O$ កាំស្មើ 1 និងរង្វង់ផ្ចិត $O$ កាំស្មើ 2



គ. វិសមីការមានតំបន់ចំលើយបិតនៅក្នុង និងលើរង្វង់ផ្ចិត $(1,0)$ កាំស្មើ 2 ។

ឃ. វិសមីការមានតំបន់ចំលើយឋិតក្នុងអង្កត់ថាស



ង.



2. ក. បន្ទាត់ $D: y = -x+2$ និង បន្ទាត់

$D': x-2y-2=0$ កាត់គ្នាត្រង់ចំណុច $(2,0)$

ខ. គូចំលើយប្រព័ន្ធសមីការ $(2,0)$

3. ក.

តំបន់ចំលើយ



ខ.

តំបន់ចំលើយក្នុងត្រីកោណ



គ.

តំបន់ចំលើយគឺផ្នែកធូត



## លំហាត់ជំពូកទី 4

1. គេឲ្យចំណុចពីរ $A(-2)$ និង $B(5)$ ។ តាង $C$ ជាចំណុចចែកក្នុងនៃ $AB$ តាមផលធៀប $3:2$ ។ និង $D$ ជាចំណុចចែកក្រៅនៃ $AB$ តាមផលធៀប $1:3$ រកប្រវែង $CD$ ។
2. រកកូអរដោនេនៃចំណុច $M$ ចែកក្នុងនិង $N$ ចែកក្រៅនៃអង្កត់ $AB$ តាមផលធៀប $1:3$ ចំពោះគូចំណុច $A(-1,3)$, $B(-2,-5)$ រួចរកប្រវែង $MN$ ។
3. រកសមីការបន្ទាត់នៃមេដ្យាទ័ររបស់អង្កត់ $AB$ ចំពោះ $A(2,3)$ និង $B(4,5)$ ។
4. សមីការនៃបន្ទាត់ $\ell_1$ និង $\ell_2$ គឺ $3x+4y-18=0$ និង $x-2y+4=0$ រៀងគ្នា ។ រកតំលៃនៃចំនួនថេរ $k$ បើបន្ទាត់ $y=kx$ កាត់តាមចំណុចប្រសព្វនៃ $\ell_1$ និង $\ell_2$ ។
5. រកតំលៃនៃចំនួនថេរ $a$ បើចំណុចទាំងបី $A(a,a+4)$, $B(-2,6)$ និង $C(7,5)$ ស្ថិតនៅលើបន្ទាត់តែមួយ ។
6. រកផ្ទៃក្រឡានៃត្រីកោណដែលខ័ណ្ឌដោយបន្ទាត់បី $x+y-7=0, 3x-2y-1=0$ និង $x-4y+3=0$ ។

7. កំណត់ផ្ចិត និងកាំនៃរង្វង់ដែលកាត់តាមបីចំណុច $A(8,4)$ , $B(3,-1)$ និង $C(6,8)$ ។

8. រកសមីការនៃបន្ទាត់ដែលកាត់តាមចំណុច $(1,5)$ ហើយប៉ះរង្វង់ $x^2+y^2=1$ ។

9. កំណត់ប្រព័ន្ធវិសមីការដែលមានតំបន់ចម្លើយស្ថិតនៅក្នុង $\Delta ABC$ ដែលមានកំពូល $A(2,0)$ , $B(-3,0)$ និង $C(0,4)$ ហើយជ្រុងនៃត្រីកោណមិនគិតបញ្ចូលទេ ។

10. រកតំលៃនៃចំនួនថេរ $a$ ឲ្យបន្ទាត់ $ax+4y=1$ និង $x+(a-3)y=2$ ស្របគ្នា ។

11. រកតំលៃចំនួនថេរ $a$ ឲ្យបន្ទាត់ $ax+y+1=0$ និងរង្វង់ $x^2+y^2+4x+3=0$ ប៉ះគ្នា ។

12. គេឲ្យចំនុចនឹងពីរ $A(2,0)$ និង $B(0,1)$ ។ រកសំណុំចំណុចនៃចំណុច $P$ ដែលផ្ទៀងផ្ទាត់ $AP:PB=2:1$ ។

13. រកកូអរដោនេនៃចំណុចប្រសព្វរវាងរង្វង់ $x^2+y^2-4y-4=0$ និង $x^2+y^2-2x=0$ ។

14. កំណត់តំលៃរបស់ $r$ ឲ្យរង្វង់ $(x-4)^2+(y-3)^2=4$ និង $x^2+y^2=r^2$ មិនមានចំណុចរួម ។

## ដំណោះស្រាយ

1. $C\left(\frac{11}{5}\right), D\left(-\frac{11}{2}\right)$ ប្រវែង $CD = 7.7$ ។
2. $M\left(-\frac{5}{4}, 1\right), N\left(-\frac{1}{2}, 7\right)$ ប្រវែង $MN = \frac{\sqrt{585}}{4}$ ។
3. $y = -x + 7$
4. $y = k = \frac{3}{2}$
5. $a = \frac{8}{5}$
6. ប្រសព្វរវាង $L_1$ និង $L_2$ គឺ $A(3,4)$

   ប្រសព្វរវាង $L_1$ និង $L_3$ គឺ $B(5,2)$

   ប្រសព្វរវាង $L_2$ និង $L_3$ គឺ $C(1,2)$

   $S \approx \sqrt{\sim 24.95} \approx 5$
7. $A = -6, B = -8$ និង $C = 0$

   $(x-3)^2 + (y-4)^2 = 5^2$ ជារង្វង់ដែលមានផ្ចិត

$I(3,4)$ និងកាំ $r = 5$ ។

8. សមីការ បន្ទាត់ប៉ះ $x=1$ និង $5y-12x-13=0$

9. $\begin{cases} y<0 \\ y<\dfrac{4}{3}x+4 \\ y<-2x+4 \end{cases}$

10. $a=1, a=4$

11. $\left(1+a^2\right)x^2+2(a\div 2)x+4=0 \quad (1)$

ដើម្បីអោយបន្ទាត់ប៉ះរង្វង់ លុះត្រាតែសមីការ $(1)$ មានរឹសឌុប

គេបាន $\dfrac{\Delta}{4}=0 \Rightarrow (a\div 2)^2-4\left(1+a^2\right)=0$

$\Rightarrow a(-3a\div 4)=0$

គេបាន $a=0, a=\dfrac{4}{3}$

12. តាងកូអរដោនេនៃចំនុច $P(x,y)$ គេបាន

$AP^2=(x-2)^2+y^2, BP^2=x^2+(y-1)^2$

$\dfrac{AP}{BP}=\dfrac{2}{1} \Rightarrow AP=2BP \Rightarrow AP^2 4BP^2$ នោះ

$$\left(x+\frac{2}{3}\right)^2+\left(y-\frac{4}{3}\right)^2=\left(\frac{2\sqrt{5}}{3}\right)^2$$

ដូច្នេះ សំណុំចំណុចនៃចំណុច $P$ ជារង្វង់ផ្ចិត

$I=\left(-\frac{2}{3},\frac{4}{3}\right)$ និងកាំ $r=\frac{2\sqrt{5}}{3}$ ។

13. កូអរដោនេនៃចំណុចប្រសព្វគឺ $(2,0)$ និង $\left(\frac{2}{5},-\frac{4}{5}\right)$ ។

14. កំណត់តំលៃរបស់ $r$ អោយរង្វង់

$(x-4)^2+(y-3)^2=0$ និង $x^2+y^2=4$ មិនមានចំណុចរួម



រង្វង់ $(x-4)^2+(y-3)^2=4$ មានផ្ចិត $I(4,3)$

រង្វង់ $x^2+y^2=r^2$ មានផ្ចិត $O(0,0)$ នោះចំងាយមានផ្ចិត $OI=5$

ដើម្បីរង្វង់ទាំងពីរគ្មានចំណុចរួម លុះត្រាតែ $2+r<5 \Rightarrow 0<r<3$ និង $r<7$ ។

# មេរៀនទី1 អនុគមន៍ និងក្រាបនៃអនុគមន៍

## មេរៀនសង្ខេប

1. ដែនកំនត់នៃអនុ. $f$ ដែលតាងដោយ $D$ គឺសំណុំអថេរ $x$ ដែលបណ្ដាលឲ្យអនុ. $y=f(x)$ មានតំលៃ ។

2. សំណុំរូបភាពនៃអនុ. $f$ ដែលតាងដោយ $I$ គឺសំណុំតំលៃ $y=f(x),\forall x$ នៅលើដែនកំនត់ $D$ ។

3. $f$ ជាអនុ.កំនត់លើចន្លោះ $[a,b]$ ។

បើ $\frac{\Delta f}{\Delta x}>0$ នោះគេថា $f$ ជាអនុ.កើនលើ $[a,b]$ ។

បើ $\frac{\Delta f}{\Delta x}<0$ នោះគេថា $f$ ជាអនុ.ចុះលើ $[a,b]$ ។

4. ដើម្បីរកអនុ.ច្រាសនៃ $f$ គេត្រូវ

- ជំនួស $f(x)$ ដោយ $y$ ។
- ប្ដូរ $x$ ជា $y$ និង $y$ ជា $x$ គេបានសមី.ថ្មី

រូបទាញរកតំលៃ $y$ ។

- បើសមីការថ្មីនេះមិនតាង $y$ ជាអនុ.នៃ $x$ ទេ នោះអនុ. $f(x)$ គ្មានអនុ.ច្រាសទេ ។
- ជំនួស $y$ ដោយ $f^{-1}(x)$ ។

5. ក្រាបនៃអនុ. $y=f(x)$ និង ក្រាបនៃអនុ.ច្រាសរបស់វាគឺ $y=g(x)$ ឆ្លុះគ្នាធៀបទៅនឹងបន្ទាត់ $y=x$ ។

## លំហាត់

1. គេមានអនុ. $f$ កំនត់លើ□ ដោយ $f(x)=x^2-4x+2$ ។ ចំពោះគ្រប់តំលៃនៃ $x\in\{-1,0,1,2\}$ ចូរកំនត់តំលៃ $f(x)$ ។

2. គេមានអនុ. $f$ កំនត់លើ□ ដោយ $f(x)=2(x-1)^2+1$ ។

គណនា $f(-1),\ 2f(1),\ f(-\frac{1}{2})$ ។

3. គេមានអនុ. $g: x\mapsto 3-2x$ ។

ដោយមានជំនួយពីក្រាប $y=3-2x$ ។

ក/ រកសំណុំរូបភាពនៃអនុ. $g$ ត្រូវនឹងដែនកំណត់

$\{x\in \square \mid -1\le x\le 2\}$ ។

ខ/ រកដែនកំណត់នៃអនុ.$g$ ត្រូវនឹងសំណុំរូបភាព

$\{x\in \square \mid -3\le y\le 2\}$ ។

4. រកដែនកំណត់នៃអនុ.ខាងក្រោម៖

$a/\ f(x)=4\sqrt{x-3}-\dfrac{3x}{\sqrt{5-x}}$, $c/\ f(x)=4\sqrt{3-2x}-\dfrac{3x}{x^2-3x+2}$

$b/\ f(x)=\sqrt{5x-4}-\dfrac{1}{x-3}$, $d/\ f(x)=\sqrt[3]{x-5}-\sqrt[4]{4-x}$

5. គេឲ្យអនុ. $f(x)=x+3, x\ge 0$ និង

$g(x)=x^2, -2\le x\le 3$ ។ រកសំណុំរូបភាពនៃអនុ. $f,g$

6. គេឲ្យអនុ. $f(x)=2x-3$ និង $g(x)=x^2+2$ ។

សិក្សាភាពកើន-ចុះ នៃអនុ. $f,g$ ដោយប្រើ $\dfrac{\Delta f}{\Delta x}$ & $\dfrac{\Delta g}{\Delta x}$ ។

7. រកអនុ.ច្រាសនៃអនុ. $f$ នីមួយៗខាងក្រោម៖

$a/\ f(x)=2x+3$, $c/\ f(x)=\dfrac{1}{x}-3,\ x\ne 0$

$b/\ f(x)=2-x$, $d/\ f(x)=\dfrac{3}{x-1}$

8. សង់ក្រាបតាងអនុ.ខាងក្រោម៖

$a/\ y=|x+1|$ $b/\ y=|x-1|+2$

9. ក. រកអនុ.ច្រាសនៃអនុ. $f(x)=x+3$ ។

ខ. សង់ក្រាបតាងអនុ. $f$ និង $f^{-1}$ ។

## ដំណោះស្រាយ

1. កំនត់តំលៃ $f(x)\ ,x\in\{-1,0,1,2\}$

យើងមាន៖ $f(x)=x^2-4x+2$

ដូចនេះ $f(-1)=7, f(0)=2, f(1)=-1, f(2)=-2$ ។

2. កំនត់តំលៃ $f(-1),\ 2f(1),\ f(-\frac{1}{2})$

យើងមាន៖ $f(x)=2(x-1)^2+1$

ដូចនេះ $f(-1)=9, 2f(1)=2, f(-\frac{1}{2})=\frac{11}{2}$ ។

3. ក. សំណុំរូបភាពនៃអនុ. $g$ គឺ $-1\le y\le 5$.

ខ. ដែនកំណត់នៃអនុ.$g$ គឺ

$$D=\left\{x\in \mathbb{R}\ /\frac{1}{2}\le x\le 3\right\}$$

4. រកដែនកំណត់នៃអនុ.ខាងក្រោម៖

$a/ D=\{x\in\mathbb{R} / 3\le x\le 5\}$, $c/ D=\left]-\infty,\frac{3}{2}\right]-\{1\}$

$b/ D=\left[\frac{4}{5},+\infty\right[-\{3\}$, $d/ D=\left]-\infty,4\right]$

5. - សំណុំរូបភាពនៃអនុ. $f$ គឺ $\{y\in\mathbb{R} / y\ge 3\}$

- សំណុំរូបភាពនៃអនុ. $g$ គឺ $\{y\in\mathbb{R} / 0\le y\le 9\}$ ។

6. $f$ ជាអនុ.កើនគ្រប់ $x_1<x_2<0$ នោះ អនុ. $g$ ចុះ គ្រប់ $0<x_1<x_2$ នោះ អនុ. $g$ កើន ។

7. អនុ.ច្រាសនៃអនុ. $f$ គឺ៖

$a/ f^{-1}(x)=\frac{x-3}{2}$, $c/ f^{-1}(x)=\frac{1}{x+3}$,

$b/ f^{-1}(x)=2-x$, $d/ f^{-1}(x)=\frac{3}{x}+1$

8. សង់ក្រាបតាងអនុ.

$a/ y=|x+1|$

$\Rightarrow D=\mathbb{R}$ ដូចនេះ $\forall x\in\mathbb{R}\Rightarrow y=|x+1|\ge 0$

គេបានសំណុំរូបភាព $i=\{y / y\ge 0\}$

នោះបើ $x \geq -1 \Rightarrow y = x+1, \quad x < -1 \Rightarrow y = -(x+1)$




$b \,/\, y = |x-1| + 2$

$\Rightarrow D = \mathbb{R}$ ដូចនេះ $\forall x \in \mathbb{R} \Rightarrow y = |x-1| + 2 \geq 0$

គេបានសំណុំរូបភាព $I = \{y \,/\, y \geq 0\}$

នោះបើ $x \geq 1 \Rightarrow y = x+1, \quad x < 1 \Rightarrow y = -(x+1)$




9. ក. អនុ.ច្រាសនៃអនុ. $f$ គឺ $f^{-1}(x)=x-3$ ។

ខ. សង់ក្រាបតាងអនុ. $f$ និង $f^{-1}$ ។



y = x + 3
y = x − 3
y = x + 3
y = x − 3
x
y
14
7
0
−7
−14
−4
−2
0
2
4

# មេរៀនទី2 អនុគមន៍ដឺក្រេទី2និងក្រាបរបស់វា

## មេរៀនសង្ខេប

1. ក្រាបតាង $y = a(x-p)^2 + q$ ជារូបកិលនៃក្រាប $y = ax^2$ ចំនួន $p$ ឯកតាស្របនឹងអ័ក្សអាប់ស៊ីស ។

- រំកិលទៅស្តាំ បើ $p > 0$ ។ - រំកិលទៅឆ្វេង បើ $p < 0$ ។

2. ក្រាបនៃអនុ. $y = a(x-p)^2 + q$ គឺជាប៉ារ៉ាបូល ដែលបានដោយរំកិលក្រាប $y = ax^2$ ស្របនឹងអ័ក្សអាប់ស៊ីសចំនួន $p$ ឯកតា ហើយ ស្របនឹងអ័ក្សអរដោនេចំនួន $q$ ឯកតា ។ ប៉ារ៉ាបូលមានកំពូល $(p,q)$ និងអ័ក្សឆ្លុះមានសមីការ $x = p$ ។

3. $$y = ax^2 + bx + c = a\left(x + \frac{b}{2a}\right)^2 - \frac{b^2 - 4ac}{4a} = a(x-p)^2 + q$$

ដែល $p = -\dfrac{b}{2a}, q = -\dfrac{b^2 - 4ac}{4a}$ ។

ក្រាបនៃអនុ. $y = ax^2 + bx + c$ ជាប៉ារ៉ាបូលដែលបាន

ដោយរំកិលក្រាប $y=ax^2$ ស្របនឹងអ័ក្សអាប់ស៊ីសចំនួន $p=-\frac{b}{2a}$ ឯកតា ហើយ ស្របនឹងអ័ក្សអរដោនេចំនួន $q=-\frac{b^2-4ac}{4a}$ ឯកតា ។ ប៉ារ៉ាបូលមានកំពូល $\left(p=-\frac{b}{2a}, q=-\frac{b^2-4ac}{4a}\right)$ និងអ័ក្សឆ្លុះមានសមីការ $x=-\frac{b}{2a}$ ។

4. ក្រាបតាង $y=a(x-p)^2+q$ គឺជាប៉ារ៉ាបូលដែលបានមកដោយរំកិលក្រាបតាង $y=ax^2$ ចំនួន $p$ ឯកតាស្របអ័ក្ស ។

ប៉ារ៉ាបូលមានកំពូល $(p, q)$ និងអ័ក្សឆ្លុះ $x=p$ ។

5. តម្លៃអតិបរមា និងអប្បបរមានៃអនុគមន៍ដឺក្រេទី2៖

$y=ax^2+bx+c$

-បើ $a>0$ នោះ អនុគមន៍មានតម្លៃអប្បបរមាស្មើ $y=-\frac{b^2-4ac}{4a}$ ត្រង់ $x=-\frac{b}{2a}$ ហើយអនុគមន៍គ្មាន

អតិបរមា ទេ ។

-បើ $a<0$ នោះ អនុគមន៍មានតម្លៃ អតិបរមាស្មើ $y=-\frac{b^2-4ac}{4a}$ ត្រង់ $x=-\frac{b}{2a}$ ហើយអនុគមន៍គ្មានអប្បបរមាទេ ។

## លំហាត់

1.សង់ក្រាបតាងអនុគមន៍ខាងក្រោម ៖

ក. $y=\frac{3}{2}x^2$ ខ. $y=-\frac{1}{3}x^2$ គ. $y=-\frac{3}{2}x^2$

2.រកអនុគមន៍ដឺក្រេទី 2 ដែលក្រាបបានដោយរំកិលក្រាបតាង $y=-3x^2$ ដែលកំពូលស្ថិតនៅលើចំនុចខាងក្រោម ៖

ក. $(-2,0)$ ខ. $(0,2)$ គ. $(-1,4)$

3.សង់ក្រាបប៉ារ៉ាបូលនីមួយៗ រកកំពូលរបស់វា និងចំនុចប្រសព្វរវាងប៉ារ៉ាបូលជាមួយអ័ក្សអាប់ស៊ីស ៖

ក. $y=3x^2-2x$ ខ. $y=(x+1)(x-3)$

គ. $y=-2x^2-4x+6$

4.កំនត់អនុគមន៍ដែលក្រាបជាប៉ារ៉ាបូលដែលផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម ៖

ក. កូអរដោនេនៃកំពូល $(3,-1)$ ហើយក្រាបកាត់តាមចំនុច$(6,0)$ ។

ខ.ក្រាបកាត់តាមបីចំណុច$(-1,-3)$ , $(0,1)$ និង $(1,3)$ ។

គ.ក្រាបកាត់តាមពីរចំនុច$(1,1)$ និង$(4,4)$ ហើយ លនៅលើអ័ក្សអាប់ស៊ីស ។

ប៉ារ៉ាបូលខាងក្រោមមានក្រាបតាង $y=ax^2+bx+c$ ។

កំនត់សញ្ញានៃ $a,b,c$ និង$\Delta=b^2-4ac$ ចំពោះក្រាបទាំងពីរខាងក្រោម ៖

ក. មានរូប ខ.មានរូប

6.កំណត់តម្លៃអតិបរមា និងអប្បបរមានៃអនុគមន៍បើវាមានដែនកំណត់ភ្ជាប់ខាងក្រោម ៖

ក. $y=3x-x^2\,(-1\le x\le 2)$ ។

ខ. $y=x^2+5x+4\,(-3\le x\le 0)$ ។

7.កំណត់ចំនួនចំនុចប្រសព្វរវាងប៉ារ៉ាបូល $y=x^2+2kx+1$ និងបន្ទាត់ $y=2x-3$ តាមតម្លៃ $k$ ។

8.សង់ក្រាបតាងអនុគមន៍ $y=|x-4|$ ។

9.គេមាន $f(x)=x^2-4x+3$ និង $f(x)=x^2-4x+3$ ។

ក.ផ្ទៀងផ្ទាត់ចំពោះ $\forall x$ , $f(x)=g(x)$

ខ.ទាញជាផលគុណកត្តានៃ $f(x)$

10.ដោះស្រាយវិសមីការខាងក្រោម ៖

ក. $x^2 > 9$ ខ. $x(x-2) < 3$

គ. $x^2 + 5x - 6 < 0$ ឃ. $2x^2 - 7x + 3 \geq 0$

ង. $4x(x-1) \leq 3$ ច. $(1-x)^2 \geq 17 - 2x$

ឆ. $(x+2)^2 < x(4-x) + 40$

11. គេមាន $f(x) = x^2 - 2x - 5$

ក. កំណត់កូអរដោនេកំពូលនៃប៉ារ៉ាបូល រួចទាញជាទម្រង់ $f(x) = (x-\alpha)^2 + \beta$ ។

ខ. សង់ប៉ារ៉ាបូលក្នុងតំរុយកូអរដោនេនៃចំនុចប្រសព្វរវាងប៉ារ៉ាបូលនិងអ័ក្សអាប់ស៊ីស ។

12. គេមានអនុគមន៍ $f(x) = x^2 + 3x - 1$ និង $g(x) = 4 - x^2$ ។

ក. សង់ក្រាបតាងអនុគមន៍ $f$ និង $g$ ក្នុងតំរុយកូអរដោនេ ។

ខ. ដោះស្រាយសមីការ $f(x) = g(x)$ រួចបកស្រាយតាមបែបក្រាភិច ។

គ. ដោះស្រាយវិសមីការ $f(x) \le g(x)$ តាមក្រាប ។

13.គេមានអនុគមន៍ $f$ កំនត់ដោយ $f(x)=|2x-1|$ ចំពោះ$-1 \le x \le 3$ ។

ក. សង់ក្រាបតាងអនុគមន៍ $f$ និងរកសំណុំរូបភាពតាងអនុគមន៍ $f$ ។

ខ.ដោះស្រាយវិសមីការ $f(x) \le 3$ ។

គ.សង់ក្រាបតាងអនុគមន៍ $y=x+1$ រួចដោះស្រាយសមីការ$|2x-1|=x+1$ តាមក្រាប ។

## ដំណោះស្រាយ

1.ក. $y=\frac{3}{2}x^2$

ក្រាបតាងអនុគមន៍ $y=\frac{3}{2}x^2$ កាត់តាមចំនុចខាងក្រោម

| $x$ | $-2$ | $-1$ | $-\frac{1}{2}$ | $0$ | $\frac{1}{2}$ | $1$ | $2$ |
|---|---|---|---|---|---|---|---|
| $y$ | $6$ | $\frac{3}{2}$ | $\frac{3}{8}$ | $0$ | $\frac{3}{8}$ | $\frac{3}{2}$ | $6$ |

ខ. $y=-\frac{1}{3}x^2$

ក្រាបតាងអនុគមន៍ $y=-\frac{1}{3}x^2$ កាត់តាមចំនុច ខាងក្រោម ៖

| $x$ | $-3$ | $-2$ | $-1$ | $0$ | $1$ | $2$ | $3$ |
|---|---|---|---|---|---|---|---|
| $y$ | $-3$ | $-\frac{4}{3}$ | $-\frac{1}{3}$ | $0$ | $-\frac{1}{3}$ | $-\frac{4}{3}$ | $-3$ |

2.ក. $(-2,0)$ អនុគមន៍ដឺក្រេទី 2 ដែលក្រាបបានមក ដោយរំកិលក្រាបតាង $y=-3x^2$ ចំនួន $-2$ ឯកតាស្រប អ័ក្សអាប់ស៊ីស និង $0$ ឯកតាស្របអ័ក្សអរដោនេគឺ $y=-3(x+2)^2$ ។

ខ. $(-2,0)$ អនុគមន៍ដឺក្រេទី 2 ដែលក្រាបបានមក

វា ក្រាបតាង $y=-3x^2$ ចំនួន $-2$ ឯកតាស្រប
អ័ក្សអាប់ស៊ីស និង 0 ឯកតាស្របអ័ក្សអរដោនេគឺ
$y=-3x^2+2$ ។

គ. $(-1,4)$ អនុគមន៍ដឺក្រេទី 2 ដែលក្រាបបានមក
ដោយរំកិលក្រាបតាង $y=-3x^2$ ចំនួន $-1$ ឯកតាស្រប
អ័ក្សអាប់ស៊ីស និង 4 ឯកតាស្របអ័ក្សអរដោនេគឺ
$y=-3(x+1)^2+4$ ។

3.ក. $y=3x^2-2$

នោះ $y=3\left(x^2-\frac{2}{3}x\right)=3\left(x-\frac{1}{3}\right)^2-\frac{1}{3}$ ប៉ារ៉ាបូល
មានកំពូល $\left(\frac{1}{3},\frac{1}{3}\right)$ ចំនុចប្រសព្វរវាងប៉ារ៉ាបូលជាមួយ
អ័ក្សអាប់ស៊ីសគឺ

$$3x^2-2x=0 \Leftrightarrow x(3x-2)=0 \Rightarrow x=0, x=\frac{2}{3}$$

ប៉ារ៉ាបូលប្រសព្វជាមួយអ័ក្សអាប់ស៊ីសត្រង់ចំណុច

$(0,0)$ និង $\left(\frac{2}{3},0\right)$ ។

ខ. $y=(x+1)(x-3)$ នោះ៖

$y=x^2-2x-3=(x-1)^2-4$ ប៉ារ៉ាបូល

មានកំពូល$(1,4)$ ប៉ារ៉ាបូលប្រសព្វជាមួយអ័ក្សអាប់ស៊ីស

ត្រង់ចំណុច$(-1,0)$ និង$(3,0)$ ។

គ. $y=-2x^2-4x+6$ នោះ៖

$y=-2\left(x^2+2x-3\right)=-2(x+1)^2+8$ ប៉ារ៉ាបូល

មានកំពូល$(-1,8)$ ប៉ារ៉ាបូលប្រសព្វជាមួយអ័ក្ស

អាប់ស៊ីសត្រង់ចំណុច$(1,0)$ និង$(-3,0)$ ។

4.ក. $y=\frac{1}{9}x^2-\frac{2}{3}x$ ខ. $y=-x^2+3x+1$

គ. $y=\frac{1}{9}x^2-\frac{4}{9}x+\frac{4}{9}$

5.កំណត់សញ្ញានៃ $a,b,c$ និង $\Delta=b^2-4ac$

$a>0$ ព្រោះភាពផតបែរទៅរកផ្នែក $y>0$

$c>0$ ព្រោះក្រាបកាត់អ័ក្សអាប់ស៊ីសត្រង់ពីរចំណុច

$b>0$ ព្រោះអាប់ស៊ីសកំពូលវិជ្ជមាន

$\Delta>0$ ព្រោះក្រាបកាត់អ័ក្សអាប់ស៊ីសត្រង់ពីរចំណុច

$a<0$ ព្រោះភាពផតបែរទៅរកផ្នែក $y<0$

$c<0$ ព្រោះក្រាបមិនកាត់អ័ក្សអាប់ស៊ីស

$b<0$ ព្រោះអាប់ស៊ីសកំពូលអវិជ្ជមាន

$\Delta<0$ ព្រោះក្រាបមិនកាត់អ័ក្សអាប់ស៊ីស

6.ក. អនុគមន៍មានតំលៃអតិបរមាស្មើ $\frac{9}{4}$ ត្រង់ $x=\frac{3}{2}$ ហើយអនុគមន៍មានតំលៃអប្បបរមាស្មើ $-4$ ត្រង់ $x=-1$ ។

ខ. អនុគមន៍មានតំលៃអប្បបរមាស្មើ $-\frac{9}{4}$ ត្រង់ $x=-\frac{5}{2}$ ហើយអនុគមន៍មានតំលៃអតិបរមាស្មើ 4 ត្រង់ $x=0$ ។

7.ចំពោះ $\frac{\Delta}{4}>0$ ឬ $k<-1$ ,នោះបន្ទាត់កាត់

តាមប៉ារ៉ាបូលត្រង់ពីរចំណុចផ្សេងគ្នា ។

ចំពោះ $\frac{\Delta}{4}=0$ ឬ $k=-1$, នោះបន្ទាត់ប៉ះជាប៉ារ៉ាបូល។

ចំពោះ $\frac{\Delta}{4}<0$ ឬ $-1<k<3$ នោះបន្ទាត់មិនកាត់ប៉ារ៉ាបូលទេ ។

9.ក. $f(x)=x^2-4x+4$

$$=x^2-2\cdot x\cdot 2+2^2-2^2+3$$

$$=(x-2)^2-1=g(x)$$

ចំពោះ $\forall x$ , $f(x)=g(x)$

ខ. $f(x)=(x-3)(x-1)$

10. ក. $x<-3, x>3$ ខ. $-1<x<3$

គ. $-6<x<1$ ឃ. $x\le\frac{1}{2}, 3\ge$

ង. $-\frac{1}{2}\le x\le\frac{3}{2}$ ច. $x\le 4, x\ge 4$

ឆ. $-3\sqrt{2}<x<3\sqrt{2}$

11.ក. ប៉ារ៉ាបូលតាង $f(x)=x^2-2x+5$ នេះមាន

កំពូល $S\left(-\frac{b}{2a},\frac{b^2-4ac}{4a}\right)$ ឬ $S(1,6)$ រូបទាញ

$f(x)=(x-1)^2-6$ ។

ខ.ដូចនេះប៉ារ៉ាបូលប្រសព្វជាមួយអ័ក្សអាប់ស៊ីសត្រង់ចំនុច $\left(1-\sqrt{6},0\right)$ ។

12. ក.



គ.វិសមភាព $f(x) \le g(x)$ តាមក្រាបមានសំណុំ

ចំលើយ $-\frac{5}{2} \le x \le 1$ ។

13. ខ. $-1 \le x \le 2$

គ. $x = 0, x = 2$ ជាឫសសមីការ

14. សំណុំរូបភាព $I = \{y / y \ge -10\}$

**មេរៀនទី3**

# អនុគមន៍សនិទាន អនុគមន៍អសនិទាន

## មេរៀនសង្ខេប

1.អនុគមន៍ $y=\frac{a}{x}$ កើនជានិច្ច ចំពោះ $a<0$ និងចុះជានិច្ចចំពោះ $a>0$ ។

ក្រាបតាង $y=\frac{a}{x}$ មានអាស៊ីមតូតដែលមានទមីការ $x=0$ , $y=0$ និងមានគល់ $O(0,0)$ ជាផ្ចិតធ្លុះ ។

2.ក្រាបតាង $y=\frac{a}{x-p}+q$ គឺជាអ៊ីពែបូលដែលបានដោយរំកិលក្រាប $y=\frac{a}{x}$ ចំនួន $p$ ឯកតា ស្របអ័ក្សអាប់ស៊ីស និងចំនួន $q$ ឯកតាស្របអ័ក្សអរដោនេ ។

អ៊ីពែបូលមាន អាស៊ីមតូតឈរនិងដេកដែលមានសមីការរៀងគ្នា $x=p$ និង $y=q$ ។

3.ក្រាបតាង $y=\sqrt{x}$ គឺជាផ្នែកប៉ារ៉ាបូលដែលជារូបឆ្លុះនៃប៉ារ៉ាបូលដែលជារូបឆ្លុះនៃប៉ារ៉ាបូល $y=x^2$ ធៀបទៅនិងបន្ទាត់ $y=x$ ហើយត្រូវនឹង $y\geq 0$ ។

4.ក្រាបតាង $y=\sqrt{ax+b}$ បានរំកិលក្រាបតាង $y=\sqrt{ax}$ ចំនួន $p=-\dfrac{b}{a}$ ឯកតាស្របអ័ក្សអាប់ស៊ីស ។

## លំហាត់

1. រកអនុគមន៍ដែលក្រាបបានដោយរំកិលក្រាបតាង $y=\dfrac{2}{x}$ ៖

ក.ចំនួន $-5$ ឯកតា ស្របអ័ក្សអាប់ស៊ីស ។

ខ. ចំនួន $-4$ ឯកតា ស្របអ័ក្សអរដោនេ ។

គ. ចំនួន $-5$ ឯកតា ស្របអ័ក្សអាប់ស៊ីស និង 5 ឯកតា ស្របអ័ក្សអរដោនេ ។

2.សង់ក្រាប និងកំណត់អាស៊ីមតូតនៃអនុគមន៍

ខាងក្រោម ៖

ក. $y=\frac{4}{x+3}$ ។

ខ. $y=4-\frac{2}{x+1}$ ។

3.កំណត់កូអរដោនេចំនុចប្រសព្វរវាងក្រាបតា $y=\frac{1}{x}$ និងបន្ទាត់ $y=\frac{5}{2}-x$ ។

4. រកអនុគមន៍ដែលក្រាបបានដោយបំលែងក្រាបតាង $y=2\sqrt{x}$ តាមរំកិលក្រាបចំនួន 2 ឯកតាស្របអ័ក្សអាប់ស៊ីសទៅឆ្វេង ។

5.សង់ក្រាបតាងអនុគមន៍ខាងក្រោម ៖

ក. $y=\sqrt{3x-5}$ ។

ខ. $y=-\sqrt{4-x}$ ។

6.រកអនុគមន៍ច្រាស និងរកដែនកំណត់តាងអនុគមន៍ $f(x)$ នីមួយៗខាងក្រោម ៖

ក. $f(x)=\frac{2}{3}x+5$ ។

ខ. $f(x)=\frac{1}{x+2}+1$ ។

គ. $f(x)=\sqrt{1-x}$ ។

ឃ. $f(x)=-\sqrt{x+4}$ ។

## ដំណោះស្រាយ

1.ក. $y=\frac{2}{x+5}$ ខ. $y=\frac{2}{x}-4$

គ. $y=\frac{2}{x-3}+5$

2.ក.អាប់ស៊ីសឈរ $x=-3$ និងអាប់ស៊ីសដេក $y=0$ ។

ខ. អាប់ស៊ីសឈរ $x=-1$ និងអាប់ស៊ីសដេក $y=4$ ។

3. កូអរដោនេចំនុចប្រសព្វគឺ $\left(\frac{1}{2},2\right)$ និង $\left(2,\frac{1}{2}\right)$ ។

4. $y=2\sqrt{x+2}$

5.ក. $y=\sqrt{3x-5}$

តារាងតំលៃលេខ

| $x$ | $\frac{5}{2}$ | 2 | 3 | 6 |
|---|---|---|---|---|
| $y$ | 0 | 1 | 2 | $\sqrt{13}$ |

ដៅចំនុចទាំងនេះរួចភ្ជាប់ គេបានក្រាបដូចខាងក្រោម



ខ. $y=-\sqrt{x-4}$

តារាងតំលៃលេខ

| $x$ | 4 | 2 | 0 | −5 |
|---|---|---|---|---|
| $y$ | 0 | $-\sqrt{2}$ | −2 | −3 |

ដៅចំនុចទាំងនេះរួចភ្ជាប់គេបានក្រាបដូចខាងលើ។

6.ក.អនុគមន៍ច្រាសនៃអនុគមន៍ $f(x)=\frac{2}{3}x+5$ គឺ

$f^{-1}(x)=\frac{3x-15}{2}$ ។ $f^{-1}$ កំណត់ចំពោះគ្រប់ចំនួនពិត $x$

ខ. អនុគមន៍ច្រាសនៃអនុគមន៍ $f(x)=\frac{1}{x+2}+1$ គឺ

$f^{-1}(x)=\frac{1}{x-1}-2$ ។ $f^{-1}$ កំណត់ចំពោះ $\{x\in \mathbb{R} \mid x\neq 1\}$

គ. អនុគមន៍ច្រាសនៃអនុគមន៍ $f(x)=\sqrt{1-x}$ គឺ

$f^{-1}(x)=1-x^2$ ។ $f^{-1}$ កំណត់ចំពោះ $\{x\in \mathbb{R} \mid x\geq 0\}$

ឃ. អនុគមន៍ច្រាសនៃអនុគមន៍ $f(x)=-\sqrt{x+4}$

គឺ $f^{-1}(x)=x^2-4$ ។ $f^{-1}$ កំណត់ចំពោះ $\{x\in \mathbb{R} \mid x\leq 0\}$

## លំហាត់ជំពូកទី 5

1.កំណត់តម្លៃ $p$ និង $q$ ដែលអនុគមន៍ $y=x^2+px+q$ មានតម្លៃអប្បបរមាត្រង់ $x=4$ និងអនុគមន៍មានតំលៃស្មើ5 ត្រង់ $x=2$ ។

2.កំណត់តម្លៃ$k$ ដែលប៉ារ៉ាបូល $y=2x^2+kx+4$ ប៉ះអ័ក្សអាប់ស៊ីស ។

3.កំណត់តំលៃ $a$ ដើម្បីអោយប៉ារ៉ាបូល $y=a(x-2)^2-3$ ប្រសព្វអ័ក្សអាប់ស៊ីសខាងអវិជ្ជមាន។

4.កំណត់សំណុំតំលៃ $p$ ដែលសមីការ $x^2-2xp+p-2=0$ មានឫសមួយវិជ្ជមាននិងឫសមួយទៀតអវិជ្ជមាន ។

5.ក្រាបតាង $y=x^2+2px+q$ កាត់តាមចំនុច $(2,1)$ និងកំពូលវានៅលើអ័ក្សអាប់ស៊ីស។ កំណត់តំលៃ $p$ និង $q$ ។

6. ចំនុច $p(x,y)$ នៅលើជ្រុង $AC$ នៃត្រីកោណ $\Delta ABC$ ដូចរូបខាងក្រោម៖

ក. គណនាក្រលាផ្ទៃ $S$ នៃចតុកោណកែងជាអនុគមន៍នៃ $x$ ។

ខ. កំណត់កូអរដោនេនៃចំនុច $P$ ដើម្បីឲ្យ $S$ មានតំលៃអតិបរមារួចគណនាតំលៃ $S$ ។




7. កំណត់សំណុំតំលៃនៃ $a$ ដែលវិសមីការ $x^2+ax+(a+3)>0$ ផ្ទៀងផ្ទាត់ចំពោះគ្រប់ $x\in\mathbb{R}$

8. កំណត់កូអរដោនេនៃចំនុចប្រសព្វរវាងក្រាបតាង $y=\sqrt{2x-1}$ និងបន្ទាត់ $y=x+k$ ចំពោះតំលៃ $k=-1$

.ក ...នៃចំនុចដែលឋិតនៅលើក្រាបតាង

- $y=-2$

ក. $(.....,0)$ ខ. $(0,......)$

គ. $(-2,......)$ ឃ. $(.......,3)$

10.កំណត់សមីការបន្ទាត់ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

.លអោយ ៖

ក.បន្ទាត់កាត់តាមពីរចំនុច $(2,-3)$ និង $(-1,-5)$ ។

ខ. បន្ទាត់កាត់តាមចំនុច $(-1,3)$ និងមានមេគុណ

ប្ញប់ទិសស្មើ2 ។

គ.បន្ទាត់ស្របនឹងអ័ក្ស $(y'y)$ កាត់ចំណុច $(2,5)$ ។

ឃ. បន្ទាត់កាត់ចំណុច $(-1,3)$ និងស្របនឹងបន្ទាត់

ីការ $y=-4$ ។

ង. បន្ទាត់កាត់ចំណុច $(1,4)$ និងកែងនឹងបន្ទាត់

$-\frac{1}{2}x+3$ ។

11. ដោះស្រាយតាមក្រាភិចប្រព័ន្ធ៖ $\begin{cases} x-2>0 \\ y\geq 0 \\ x-y-4<0 \\ x+2y-16\leq 0 \end{cases}$

12. គេមានអនុគមន៍ $f$ និង $g$ កំណត់ដោយ ៖

$f(x)=-(x+2)^2+4$ និង $g(x)=\dfrac{2}{x-3}+1$ ។

សង់ខ្សែកោងតាង $f$ និង $g$ ។

13. ក. សង់ក្រាបតាងប៉ារ៉ាបូល $(P): y=x^2$ អ៊ីពែបូល $(H): y=\dfrac{1}{x}$ និងបន្ទាត់ $(D): y=\dfrac{1}{2x}+\dfrac{1}{2}$ ក្នុងតំរុយតែមួយ ។

ខ. ដោយមានជំនួយពីក្រាភិចខាងលើ ចូរដោះស្រាយសមីការ និងវិសមីការខាងក្រោម ៖

(1). $x^2=\dfrac{x+1}{2}$ (2). $x^2=\dfrac{1}{x}$

(3). $\dfrac{x+1}{2}=\dfrac{1}{x}$ (4). $2x^2\geq x+1$

(5). $\dfrac{2}{x}>x+1$ (6). $x^2<\dfrac{1}{x}$

14.គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ៖

$f(x)=2x^3+12x-3$ ។ កំណត់ចំនួនពិត $a,\alpha,\beta$

ដែល $f(x)=a(x-\alpha)^2+\beta$ ។

15.គេមានប៉ារ៉ាបូល $(P): y=ax^2+bx+c$ កាត់

តាមចំណុច $A(-1,0)$ , $B(1,3)$ និង $C(3,4)$ និងបន្ទាត់

$(D): y=x+2$ ។

ក. កំណត់ចំនួនពិត $a,b$ និង $c$ រួចសង់ក្រាបតាង

ប៉ារ៉ាបូល ។

ខ.ដោះស្រាយវិសមីការ $-\frac{1}{4}x^2+\frac{3}{2}x+\frac{7}{4}\le x+2$

តាមក្រាភិច ។

## ដំណោះស្រាយ

1. $p=-8, q=17$

2. $k=\pm 4\sqrt{2}$

3. គ្មាន $a$

4. $p < 2$

5. ចំពោះ $p = -1$ នោះ $p = 1$

ចំពោះ $p = -3$ នោះ $p = 9$

6.ក.គណនាក្រលាផ្ទៃ $S$ នៃចតុកោណកែងជាអនុគមន៍នៃ $x$

$S = S_{OSPT} + S_{OTQR} = xy + y + TQ$ ដែល $0 < x < 3$

ដូចនេះ $S = -6x^2 + 18x, 0 < x < 3$ ។

ខ. $S$ មានតំលៃអតិបរមាស្មើ $\frac{27}{2}$ ចំពោះ $x = \frac{3}{2}$

។អរដោនេនៃចំនុច $p\left(\frac{3}{2}, 2\right)$ ។

$2 < a < 6$

8.សង់ក្រាបតាង $y = \sqrt{2x-1}$ តារាងតំលៃលេខ

| $x$ | $\frac{1}{2}$ | 1 | 3 | 5 |
|---|---|---|---|---|
| $y$ | 0 | 1 | $\sqrt{5}$ | 3 |

ដៅចំណុចទាំងនេះរួចភ្ជាប់ គេបានក្រាបដូចខាងស្តាំ

បន្ទាត់ $y=x-1$ កាត់តាមចំនុច$(0,1)$ និង$(1,0)$

តាមក្រាបគេបានគូអរដោនេចំណុចប្រសព្វ

$2+\sqrt{1},1+\sqrt{2}$ ។

9.បំពេញគូនៃចំនុចដែលឋិតនៅលើក្រាបតាង

$2x-y=-2$

ក. $(-1,0)$

ខ. $(0,2)$

គ. $(-2,2)$

ឃ. $\left(\frac{1}{2},3\right)$

10.ក. $y=\frac{2}{3}x-\frac{13}{3}$

ខ. $y=2x+5$

គ. $x=2$

ឃ. $y=3$

ង. $y=2x+2$

11.



12. សង់ខ្សែកោងតាង $f(x)=-(x+2)^2+4$

ក្រាបតាងអនុគមន៍ $f(x)=-x^2$ ជាប៉ារ៉ាបូល

កាត់តាមចំណុច

| | | | | | |
|---|---|---|---|---|---|
| $x$ | $-2$ | $-1$ | $0$ | $-1$ | $2$ |
| $y$ | $-4$ | $-1$ | $0$ | $-1$ | $-4$ |



$g(x)=\frac{2}{x-3}+1$



13.ក.សង់ក្រាបតាងប៉ារ៉ាបូល $(P): y=x^2$ អ៊ីពែបូល $(H): y=\frac{1}{x}$ និងបន្ទាត់ $(D): y=\frac{1}{2}x+\frac{1}{2}$ ក្នុងតំរុយ

. តួអរដោនេតែមួយក្រាបតាងប៉ារ៉ាបូល $(P): y=x^2$

| $x$ | $-2$ | $-1$ | $-\frac{1}{2}$ | $0$ | $\frac{1}{2}$ | $1$ | $2$ |
|---|---|---|---|---|---|---|---|
| $y$ | $-4$ | $-1$ | $-\frac{1}{4}$ | $0$ | $\frac{1}{4}$ | $1$ | $4$ |

អ៊ីពែបូល $(H): y=\frac{1}{x}$ មានដែនកំណត់ $\{x|x\neq 0\}$

កាត់តាមចំណុច

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| $x$ | $-4$ | $-2$ | $-1$ | $-\frac{1}{2}$ | $-\frac{1}{4}$ | $\frac{1}{4}$ | $\frac{1}{2}$ | $1$ | $1$ | $4$ |
| $y$ | $-\frac{1}{4}$ | $-\frac{1}{2}$ | $-1$ | $-2$ | $-4$ | $4$ | $2$ | $1$ | $\frac{1}{2}$ | $\frac{1}{4}$ |

$(D): y=\frac{1}{2}x+\frac{1}{2}$ កាត់ចំនុច $\left(0,\frac{1}{2}\right)$ និង $(-1,0)$

ខ. ដោយមានជំនួយពីក្រាភិចខាងលើ ដោះស្រាយ សមីការ និងវិសមីការខាងក្រោម៖

(1). $x^2=\frac{x+1}{2}$ (2). $x^2=\frac{1}{x}$

(3). $\frac{x+1}{2}=\frac{1}{x}$ (4). $2x^2\geq x+1$

(5). $\frac{2}{x}>x+1$ (6). $x^2<\frac{1}{x}$

(1).តាមក្រាបភិចសមីការ $x^2=\frac{x+1}{2}$ មានឫស $x=-\frac{1}{2}, x=1$

(2). តាមក្រាបភិចសមីការ $x^2=\frac{1}{x}$ មានឫស $x=1$

(3). តាមក្រាបភិចសមីការ $\frac{x+1}{2}=\frac{1}{x}$ មានឫស $x=2, x=1$

(4). តាមក្រាបភិចសមីការ $2x^2 \geq x+1$ មានសំណុំឫស $x \in \left]-\infty, -\frac{1}{2}\right] \cup [1, +\infty[$

(5). តាមក្រាបភិចសមីការ $\frac{2}{x} > x+1$ មានសំណុំឫស $x \in ]-\infty, -2[ \cup \left]0, \frac{1}{2}\right[$

(6). តាមក្រាបភិចសមីការ $x^2 < \frac{1}{x}$ មានសំណុំឫស $x \in ]0,1[$ ។

14. $f(x)=2x^3+12x-3=2(x^2+6x)-3$

$= 2\left(x^2 + 6x\right) - 21$ ហើយ $f(x) = a(x-\alpha)^2 + \beta$

នោះ $2\left(x^2 + 6x\right) - 21 = a(x-\alpha)^2 + \beta$ ផ្ទៀងផ្ទាត់គ្រប់

$x$ គេបាន $a = 2, \alpha = -3, \beta = -21$ ។

15.ក. $a = -\frac{1}{4}, b = \frac{3}{2}, c = \frac{7}{4}$ ហើយ

$(P): \left(y = \frac{1}{4}x^2\right) + \frac{3}{2}x + \frac{7}{4}$

ខ.សំណុំឫសវិសមីការ $x \in \mathbb{R}$

# សូមរង់ចាំរកជាវបន្តនូវភាគទី២បន្តទៀត និង កំណែរូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ដែលនឹងចេញផ្សាយឆាប់នេះ!